# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*"ការផិនណាយនៃការធ្វើសង្គ្រាម ជាទស្សនៈរបស់ពួកខ្ញុំ ឮសូរតែសន្តិភាពហ្នឹង ចង់បានមហាសាលហើយ។ ដូច្នេះព្រឹត្តិការណ៍ពេលនោះ ខ្ញុំនៅមានអារម្មណ៍ថា នឹងអាចឈានដល់ព្រឹត្តិការណ៍ដែលយើងកាត់ស្មានមិនបានទេ។"*[1]

***-សាក្សី ស៊ុម អាឡាត់***

## ផ្នែកទី ១ ៖ ទិដ្ឋភាពទូទៅ

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ បានគ្រោងស្តាប់សក្ខីកម្មរបស់សាក្សីបួនរូប ក្នុងរយៈពេលតែបួនថ្ងៃ។ សាក្សីបួនរូបរួមមាន៖ លោក **ពេជ្រ ជឹម** លោក **ឡេវ ឡាំ** លោក **ឯក ហេន** និងលោក **ស៊ុម អាឡាត់** បានផ្តល់សក្ខីកម្មសំខាន់ៗ លើការចោទប្រកាន់ចំពោះតួនាទីរបស់សហជនជាប់ចោទ ការបោសសម្អាតមន្ត្រី **លន់ នល់** និងការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហម។ ពេញមួយសប្តាហ៍នេះ ភាគីទាំងអស់ បានលើកឡើងនូវការជំទាស់មួយចំនួន ដែលផ្តោតសំខាន់ទៅលើសំណួរនាំមុខសំណួរច្រំដែល ហើយនិងសំណួរដែលមានលក្ខណៈឧបមា បន្ថែមពីលើនេះទៅទៀត ក៏មានការជំទាស់ផងដែរនូវសំណួរមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១។ អង្គជំនុំជម្រះ ក៏បានដាក់កំហិតយ៉ាងតឹងរ៉ឹងឲ្យសួរសំណួរ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងបានខិតខំយ៉ាងខ្លាំង ដើម្បីរក្សាពេលវេលារបស់សវនាការឲ្យស្របតាមកាលវិភាគដែលបានកំណត់គ្រោងទុកជាមុន។ អ្នកឃ្លាំមើលសវនាការបានកត់សម្គាល់ថា ការរឹតបន្តឹងនេះ អាចបណ្តាលឲ្យកើតមានបញ្ហានីតិវិធីគ្រប់គ្រងសវនាការមួយចំនួន បន្តរហូតដល់ចុងសប្តាហ៍នេះ។

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

សាក្សី **ពេជ្រ ជឹម** សាក្សី **ឡេវ ឡាំ** ហើយនិងសាក្សី **ឯក ហេន** គឺជាអតីតសមាជិកខ្មែរក្រហមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សី **ពេជ្រ ជឹម** ជាអតីតអនុលេខាធិការនៅស្រុកត្រាំកក់ និងបានផ្តល់សក្ខីកម្មពីការបាត់ខ្លួនរបស់ទាហាន **លន់ នល់** និងការទំនាក់ទំនង ហើយនិងរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងស្រុករបស់គាត់។ សាក្សី **ឡេវ ឡាំ** គឺជាអតីតទាហានខ្មែរក្រហម បានរៀបរាប់ពីរបៀបដែលគាត់បានយកមន្ត្រី **លន់ នល់**

ទៅវាលពិឃាដ ហើយជាកន្លែងដែលគាត់ជឿជាក់ថា ក្រោយមក កងទ័ពខ្មែរក្រហមបានសម្លាប់ពួកគេ។ សាក្សី **ឯក ហេន** គឺជាអ្នកធ្លាប់ធ្វើការនៅរោងចក្រកាត់ដេរសម្លៀកបំពាក់នៅទីក្រុងភ្នំពេញ ដែលត្រូវបានគេស្គាល់ថាជា ក-៩ បានផ្តល់សក្ខីកម្មថា គាត់បានស្តាប់ការបង្រៀនដែលបានផ្តល់ដោយសហជនជាប់ចោទក្នុងអំឡុងពេលវគ្គសិក្សាមួយចំនួន ដែលអ្នកស្រីបានចូលរួមនៅបុរីកីឡា។ អ្នកស្រី ក៏បានរម្លឹកពីរបៀបដែលមិត្តរួមការងាររបស់គាត់ត្រូវបានគេចាប់ខ្លួនផងដែរ។ សាក្សីទីបួន និងចុងក្រោយគេ គឺសាក្សី **ឡេវ ឡាំ** ដែលជាអតីតទាហាន **លន់ នល់** បានប្រាប់តុលាការថា គាត់ធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំក្នុងឆ្នាំ១៩៧៥ ជាកន្លែងដែលមន្ត្រី **លន់ នល់** បានជួបជុំ និងបញ្ជូនទៅទួលពោធិ៍ជ្រៃ ដើម្បីសម្លាប់។

## ក. សក្ខីកម្មរបស់សាក្សី ពេជ្រ ជឹម (អត្តលេខ TCW-505)

កាលពីថ្ងៃចន្ទ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី **ពេជ្រ ជឹម** ដែលជាអតីតអនុលេខាធិការ និងលេខាធិការស្រុក សម្រាប់ការឃោសនា និងការអប់រំ នៅស្រុកត្រាំកក់ ដែលត្រូវបានគេស្គាល់ផងដែរថា "ស្រុក១០៥" ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។[2]សាក្សីបានផ្តល់សក្ខីកម្មពីរចនាសម្ព័ន្ធរដ្ឋបាលខ្មែរក្រហម មន្ទីរសន្តិសុខក្រាំងតាចាន់ ការចោទប្រកាន់នៃមន្ត្រី **លន់ នល់** និងតួនាទីរបស់ជនជាប់ចោទ **នួន ជា** ដែលជាគ្រូបង្រៀននៅវគ្គសិក្សាអប់រំដល់កម្មាភិបាល។

### *ក.១. តួនាទីរបស់សាក្សីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

មុនពេលចូលរួមជាមួយខ្មែរក្រហម នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧០ សាក្សី **ពេជ្រ ជឹម** បានបម្រើការងារជាគ្រូបង្រៀនម្នាក់។ សាក្សីបានពន្យល់ថា គាត់បានចូលរួមជាមួយខ្មែរក្រហម ដោយសារតែគាត់បានខឹងនឹងរដ្ឋប្រហារ **លន់ នល់** ហើយគាត់ចង់ឲ្យ **សម្តេចសីហនុ** ស្តារអំណាចឡើងវិញ។ សាក្សីបានរៀបរាប់ពីរបៀបដែលខ្មែរក្រហមកៀងគោគ្រូបង្រៀន ដែលចាប់អារម្មណ៍ចូលរួមកងកម្លាំងចលនាមុខ និងបញ្ជូនពួកគេទៅក្នុងព្រៃដើម្បីរៀនសូត្រជាមួយអង្គការ។ សាក្សីមានតួនាទីជាអនុលេខាធិការស្រុក១០៥ បានពន្យល់ថា គាត់បានទទួលបញ្ជាឲ្យទទួលជនភៀសខ្លួនមកពីទីក្រុងភ្នំពេញ ដោយការផ្តល់ម្ហូបអាហារឲ្យពួកគេ និងចាត់ចែងពួកគេឲ្យចូលទៅក្នុងសហករណ៍។ សាក្សីបានប្រាប់តុលាការថា គាត់បានទទួលបញ្ជាក្នុងអំឡុងពេលនៃកិច្ចប្រជុំមួយក្នុងឃុំពោធិ៍ពេ មុនការជម្លៀសចេញពីទីក្រុងភ្នំពេញ។ សាក្សីបានរៀបរាប់លម្អិតពីតួនាទីរបស់គាត់ជាលេខាធិការរងស្រុក ហើយក៏បានជម្រាបតុលាការ អំពីរបៀបដែលស្រុក១០៥ បានទទួលរង្វាន់ទង់ក្រហម ដែលជាលទ្ធផលនៃការសម្បូរស្រូវ។ រង្វាន់នេះ គឺ "ស្រដៀងគ្នាទៅនឹងមេដាយមាស" ហើយសាក្សី **ពេជ្រ ជឹម** បានទទួលវាដោយផ្ទាល់ពី **តា ម៉ុក** នៅក្នុងកម្មវិធីសាធារណៈមួយ។[3] បន្ថែមពីតួនាទីជាលេខាធិការរងស្រុករបស់គាត់ សាក្សី **ពេជ្រ ជឹម** ក៏មានតួនាទីជាលេខាធិការស្រុក សម្រាប់ការឃោសនា និងការអប់រំនៅក្នុងស្រុក១០៥ ផងដែរ។

### *ក.២. ការសម្លាប់មន្ត្រី លន់ នល់*

ទាក់ទងនឹងការបោសសម្អាតទាហាន **លន់ នល់** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យសាក្សី **ពេជ្រ ជឹម** បានរៀបរាប់ពីរបៀបដែលប្រពន្ធរបស់អតីតទាហាន **លន់ នល់** បានធ្វើការតវ៉ាថា ប្តីរបស់ពួកគេបានបាត់ខ្លួន ហើយត្រូវ "បាននាំខ្លួនទៅ ដោយអង្គការ"[4]។ លោក **វិចទ័រ កូប៉េ** (Mr. Victor Koppe) មេធាវីការពារក្តី

ឲ្យលោក **នួន ជា** បានបញ្ជាក់បន្ថែមលើបញ្ហានេះ ដោយលើកឡើងថា សាក្សីបានបញ្ជាក់ថា គាត់មិនធ្លាប់បានចូលរួមផ្ទាល់នៅក្នុងការសម្លាប់មន្ត្រី **លន់ នល់** ឬធ្លាប់បានឃើញការសម្លាប់ណាមួយទេ។ សាក្សី **ពេជ្រ ជឹម** បានពន្យល់ថា ព័ត៌មានអំពីបញ្ហានេះ ត្រូវបានចែកចាយតាមរយៈពាក្យចចាមអារ៉ាម។ គាត់បាននិយាយថា "វាមិនត្រូវបាននិយាយដោយបើកចំហឡើយ ហើយបើយើងនិយាយដោយបើកចំហ បន្ទាប់មកយើងនឹងចាប់ខ្លួន"[5]។ សាក្សីបានអះអាងថា ខ្លួនមិនបានដឹងពីការអប់រំសាឡើងវិញសម្រាប់ប្រជាជនស៊ីវិល និងកងទ័ពខុសប្លែកគ្នាយ៉ាងណាទេ តែគាត់បានបន្ថែមថា គាត់ធ្លាប់តែឮអំពីការអប់រំប្រជាជនស៊ីវិលឡើងវិញ។ ក៏ប៉ុន្តែ សាក្សីបានទទួលស្គាល់ថា គាត់បានស្គាល់កងទ័ពមួយចំនួនដែលបានបាត់ខ្លួន ហើយគាត់មិនបានដឹងថា មានអ្វីកើតឡើងចំពោះពួកគេទេ។

### *ក.៣. រចនាសម្ព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធរដ្ឋបាល*

ផ្អែកលើសេចក្តីថ្លែងការណ៍របស់សាក្សី ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតព្រះរាជអាជ្ញា **រេយ៍នឺរ** បានស្នើសុំឲ្យសាក្សី **ពេជ្រ ជឹម** ឲ្យបញ្ជាក់ថា តើវាជាបទដ្ឋានអនុវត្តសម្រាប់តំបន់ដើម្បីពិគ្រោះយោបល់ជាមួយគណៈស្រុក មុននឹងចេញបញ្ជាដាច់ខាតចុងក្រោយ សម្រាប់អនុវត្តន៍ចំពោះបញ្ហាបរាជ័យក្នុងការអប់រំសាឡើងវិញ។ សាក្សីបានបញ្ជាក់ថា គណៈស្រុកគ្រាន់តែរាយការណ៍ទៅឲ្យគណៈតំបន់ និងគោរពតាមសេចក្តីណែនាំគ្រប់យ៉ាងដែលត្រូវបានបញ្ជាដោយគណៈតំបន់។ ទាក់ទងទៅនឹងការចាប់ខ្លួន សាក្សី **ពេជ្រ ជឹម** បានបន្ថែមថា គណៈស្រុក មិនបានទទួលការណែនាំណាមួយពីគណៈតំបន់ ឲ្យចាប់ខ្លួនមនុស្សនោះទេ ប៉ុន្តែ ត្រូវបានបង្ខំឲ្យនៅស្ងៀម នៅពេលដែលគណៈតំបន់មកធ្វើការចាប់ខ្លួន។ នៅពេលដែលសាក្សីបានទទួលបញ្ជា ដែលមានលក្ខណៈផ្ទុយ សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានដាក់សំណើ ឬធ្វើរបាយការណ៍ផ្ទាល់មាត់ តាមរយៈគណៈស្រុក ដើម្បីស្នើសុំធ្វើការដោះលែងប្រជាពលរដ្ឋមួយចំនួន ដែលគាត់បានជឿថា ជាជនគ្មានកំហុស។[6] សាក្សី **ពេជ្រ ជឹម** ក៏បានរម្លឹកដែរថា លេខាធិការគណៈតំបន់ (លោក **តា សួង**) បានបន្ទោសគាត់ បន្ទាប់ពីគាត់បានដោះលែងមនុស្សម្នាក់ ឈ្មោះ "**វុន**" ដែលត្រូវបានចោទប្រកាន់ថា ជាជនក្បត់។ សាក្សីបានពន្យល់ថា គាត់ធ្លាប់ធ្វើការយ៉ាងជិតស្និទ្ធជាមួយបុគ្គល **វុន** ហើយសាក្សីជឿជាក់ថា បុគ្គលនេះ មិនបានប្រព្រឹត្តិបទឧក្រិដ្ឋណាមួយប្រឆាំងនឹងអង្គការទេ។

### *ក.៤. ការអប់រំប្រជាជនស៊ីវិល និងការអប់រំឡើងវិញ*

ពេលដែលមេធាវី **កូប៉េ** បានសួរសាក្សីអំពីអត្ថន័យនៃ "ការអប់រំ" និង "ការអប់រំឡើងវិញ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាក្សី **ពេជ្រ ជឹម** បានពន្យល់ថា ពាក្យ "អប់រំ" និង "រៀនសូត្រ" អាចត្រូវបានប្រើផ្លាស់ប្តូរគ្នា ក៏ប៉ុន្តែ "ការអប់រំឡើងវិញ" មានន័យថាមនុស្សម្នាក់នោះអាចនឹងត្រូវគេយកទៅកែប្រែ។[7] ដើម្បីជៀសវាងការធ្វើខុស ឬប្រព្រឹត្តកំហុសណាមួយ សាក្សីបានថ្លែងថា មនុស្សដំបូងតម្រូវឱ្យចូលរួមវគ្គសិក្សារៀនសូត្រ ដែលពួកគេត្រូវបានណែនាំពីរបៀបធ្វើ "ល្អ" និងធ្វើ "ត្រឹមត្រូវ" ទាំងកាយ និងចិត្ត។ នៅពេលដែលមនុស្សម្នាក់បានប្រព្រឹត្តអ្វីខុស មនុស្សម្នាក់នោះនឹងត្រូវទទួលការអប់រំឡើងវិញ។ ប្រសិនបើទទួលបានជោគជ័យពីវគ្គអប់រំហើយ បុគ្គលនេះនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងសង្គមវិញ ដើម្បីអនុវត្តភារកិច្ចធម្មតា។ ហើយក៏មានសួរបន្ថែមថា តើមានអ្វីដែលអាចនឹងកើតឡើង ប្រសិនបើមនុស្សម្នាក់បានបរាជ័យក្នុងការអប់រំឡើងវិញ សាក្សីបានថ្លែងថា មនុស្សនេះនឹងត្រូវអប់រំឡើងវិញម្តងហើយម្តងទៀតរហូតដល់គាត់អាចកែប្រែខ្លួនគាត់។

### ក.៥. មន្ទីរសន្តិសុខក្រាំងតាចាន់

ក្នុងពេលផ្តល់សក្ខីកម្ម សាក្សីបានប៉ាន់ស្មានថា បក្ស (គណៈតំបន់ ឬគណៈស្រុក) បានបង្កើតមន្ទីរសន្តិសុខក្រាំងតាចាន់ នៅដើមឆ្នាំ១៩៧២។ ក៏ប៉ុន្តែ សាក្សីបានប្រាប់តុលាការថា គាត់បានដឹងថាមានមន្ទីរសន្តិសុខក្នុងឆ្នាំ១៩៧៣ តាមរយៈទំនាក់ទំនងរវាងថ្នាក់ដឹកនាំជាន់លើ។ យោងតាមសាក្សី គោលបំណងដែលមានមន្ទីរសន្តិសុខ គឺដើម្បីអប់រំឡើងវិញពី "មនុស្សអាក្រក់" ហើយប្តូរទៅជា "មនុស្សល្អ" ម្នាក់។[8] សាក្សី **ពេជ្រ ជឹម** មិនអាចផ្តល់ព័ត៌មានលម្អិតពីនិយមន័យរបស់មនុស្សអាក្រក់ ឬមូលហេតុដែលគេត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ តែសាក្សីគ្រាន់តែដឹងទូទៅថា មនុស្សទាំងនោះ គឺជាអ្នកប្រឆាំងនឹងរបបនេះ។ ទោះបីជា សាក្សីបានផ្តល់សក្ខីកម្មថា គាត់មិនដែលបញ្ជូនមនុស្សដោយផ្ទាល់ទៅមន្ទីរសន្តិសុខ ក៏ប៉ុន្តែគាត់បានអះអាងថា គាត់ត្រូវបានគេសួរម្តងម្កាលដោយមន្ត្រីជាន់ខ្ពស់នៃគណៈតំបន់ឲ្យរាយការណ៍ពីការឃុំខ្លួនមនុស្ស ប្រសិនបើ ការអប់រំឡើងវិញ មិនបានទទួលជោគជ័យ។ នៅពេលដែលវាកើតឡើង គាត់បាននិយាយថា គាត់បានស៊ើបអង្កេតករណីនេះ និងបានរាយការណ៍ដល់គណៈតំបន់ ក៏ប៉ុន្តែ គាត់មិនបានចូលរួមដំណើរការនៃការធ្វើសេចក្តីសម្រេចឡើយ។ សាក្សីបានទទួលស្គាល់ថា ទោះបីជាគាត់មិនអាចបដិសេធបញ្ជារបស់គណៈតំបន់ក្នុងការឃុំខ្លួនមនុស្សដែលបានជ្រើសរើសឲ្យឃុំខ្លួន ក៏ប៉ុន្តែ គាត់អាចដោះលែងអ្នកជាប់ឃុំឃាំងមួយចំនួនបាន ដោយផ្អែកលើរបាយការណ៍ដែលល្អ។

### ក.៦. តួនាទីរបស់ជនជាប់ចោទ នួន ជា

សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានជួបជនជាប់ចោទ **នួន ជា** តែម្តងគត់ ក្នុងវគ្គសិក្សាមួយសម្រាប់ពួកកម្មាភិបាលកម្រិតគណៈស្រុក ដែលប្រារព្ធធ្វើឡើងនៅបុរីកីឡា។ សាក្សី **ពេជ្រ ជឹម** បានពន្យល់ថា ជនជាប់ចោទ **នួន ជា** បានបង្រៀនអ្នកចូលរួមអស់រយៈពេលបីសប្តាហ៍ជាប់គ្នា ដែលសាក្សីបានសន្មតថា បានធ្វើឡើងនៅខែធ្នូ ឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦។ ដោយមានការសួរបញ្ជាក់ពីមេធាវីការពារក្តីថា តើសាក្សីបានដឹងថាជាជនជាប់ចោទ **នួន ជា** ដោយរបៀបណា? សាក្សីបានរម្លឹកថា គាត់មិនដែលត្រូវបានគេណែនាំឲ្យស្គាល់ឈ្មោះនោះទេ ប៉ុន្តែ សាក្សីបានដឹងថា គាត់គឺជាជនជាប់ចោទ **នួន ជា** ឬបងធំទីពីរ។[9]

### ក.៧. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី

នៅពេលផ្តល់សក្ខីកម្មរបស់គាត់ សាក្សីបានធ្វើសេចក្តីថ្លែងការណ៍ជាច្រើនដែលផ្ទុយពីបទសម្ភាសន៍ពីមុនរបស់គាត់ ដែលបានធ្វើនៅការិយាល័យសហចៅក្រមស៊ើបអង្កេត រួមមាន៖ មតិយោបល់ដែលគាត់បានធ្វើដើម្បីកំណត់អត្តសញ្ញាណខ្មាំង ភាពចាំបាច់នៃការរាយការណ៍មនុស្សនៅក្រាំងតាចាន់ ហើយនិងដំណើរការនៃការឃុំឃាំងប្រជាជន។ អ្នកឃ្លាំមើលសវនាការ បានកត់សម្គាល់ផងដែរថា ជាញឹកញាប់ គាត់បានផ្តល់ការឆ្លើយតបជាទូទៅនឹងសំណួរដែលជាក់លាក់ ហើយលោកប្រធានក៏បានជូនដំណឹងឲ្យសាក្សីឆ្លើយឲ្យបានលឿនជាងមុន បន្ទាប់ពីសាក្សីបាននៅស្ងៀមយ៉ាងយូរ។ បន្ទាប់ពីការប្រើប្រាស់សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងមកលើខ្លួនឯង (មកលើសាក្សី) អនុលោមតាមវិធានផ្ទៃក្នុង ២៨ សាក្សីបានព្យាយាមទាមទារឱ្យមានមេធាវីប្រឹក្សា ដើម្បីឆ្លើយតបជំនួសគាត់ នៅពេលដែលមេធាវី **កូប៉េ** បានសួរពីរបៀបដែលសាក្សីបានដឹងថា ប្រជាជនស៊ីវិល និងកងទ័ព ត្រូវបានប្រព្រឹត្តខុសគ្នានៅក្នុងការអប់រំឡើងវិញ (សូមមើលផ្នែក ៣.ក) ។

## ខ. សក្ខីកម្មរបស់ ឡេវ ឡាំ (អត្តលេខ TCW-386)

នៅថ្ងៃអង្គារ សាក្សី **ឡេវ ឡាំ** ជាកងជីវពលខ្មែរក្រហមមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានចាប់ផ្តើមផ្តល់សក្ខីកម្ម។[10] សក្ខីកម្មរបស់សាក្សី បានផ្តោតលើបញ្ហាការមកដល់នៃជនភៀសខ្លួន ១៧ មេសា ដែលមកដល់ឃុំរបស់គាត់ ក្នុងស្រុកកំពង់ត្រឡាចលើ និងការប្រព្រឹត្តិលើមន្ត្រី **លន់ នល់**។

### *ខ.១. បទពិសោធន៍ជាកងជីវពល មុនឆ្នាំ១៩៧៥*

សាក្សី **ឡេវ ឡាំ** បានរម្លឹកថា ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ គាត់បានបម្រើការងារជាសមាជិកនៃកងជីវពល ក្នុងខេត្តកំពង់ឆ្នាំង។ ក្នុងអំឡុងពេលនោះ គាត់ត្រូវបានចាត់ឱ្យទៅបម្រើការងារ នៅឃុំឈូកស្វាយ ជាកន្លែងដែលគាត់បានដាំស្រូវ ដំឡូង និងបេះផ្លែដូង។ សាក្សី **ឡេវ ឡាំ** បានផ្តល់សក្ខីកម្មថា គាត់មានមេពីរនាក់ ខណៈដែលគាត់នៅឃុំស្វាយឈូក ប្រធានឃុំ គឺឈ្មោះ **ណាន** និងជាប្រធាននៃគណៈ១២ស្រុក គឺឈ្មោះ **ស្រ៊ុន**។ សាក្សីបានពន្យល់ថា **ណាន** បានផ្តល់ភារកិច្ចទៅកងជីវពល បន្ទាប់ពីគាត់បានទទួលការបញ្ជាពី **ស្រ៊ុន**។ សាក្សីមិនបានដឹងពីខ្មែរក្រហមជាន់ខ្ពស់ផ្សេងទៀត ក្រៅតែពីប្រធាននៃគណៈតំបន់របស់គាត់ ដែលឈ្មោះថា **តា សារុន**។ ទោះបីជាកាលបរិច្ឆេទពិតប្រាកដនៅតែមិនទាន់ច្បាស់ បើយោងតាមសក្ខីកម្មរបស់សាក្សីក៏ដោយ ក៏សាក្សី **ឡេវ ឡាំ** ត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅអង្គភាពចល័តរបស់ឃុំក្នុងឆ្នាំ១៩៧៥។

### *ខ.២. ការមកដល់នៃជនភៀសខ្លួន ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

សាក្សី **ឡេវ ឡាំ** បានប្រាប់ថា មួយសប្តាហ៍ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រមាណជា ២០០ ទៅ៣០០គ្រួសារនៃជនភៀសខ្លួន មកពីខេត្តកំពង់ឆ្នាំង និងទីក្រុងភ្នំពេញ ត្រូវបានជម្លៀសមកដល់ឃុំរបស់គាត់។ ពួកគេត្រូវបានផ្លាស់ទៅភូមិគ្រង់សង្កែ និងត្រូវបានបង្ខំឱ្យរស់នៅក្រោមផ្ទះរបស់អ្នកភូមិ ឬនៅក្រោមដើមឈើ។ សាក្សីបានរម្លឹកថា គ្រួសារកសិករមួយមកពីខេត្តកំពង់ឆ្នាំង បានជ្រកកោននៅផ្ទះរបស់គាត់។ ទោះបីជាសាក្សីបានអះអាងថា គាត់មិនបាននៅច្រើនជាមួយនឹងគ្រួសារក៏ដោយ ក៏គាត់បានពន្យល់ថា គាត់បានដឹងពីព័ត៌មានក្រុមគ្រួសាររបស់គាត់ពីឪពុករបស់គាត់។ នៅពេលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី **បេនី យេ** (Ms. Beini Ye) បានសួរគាត់អំពីទំនាក់ទំនងរវាង "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី" នៅក្នុងភូមិ សាក្សី **ឡេវ ឡាំ** បានអះអាងថា អ្នកភូមិមានអារម្មណ៍ថា អាណិតអ្នកចំណូលថ្មី ហើយពេលខ្លះក៏បានផ្តល់ម្ហូបអាហារឱ្យពួកគេទៀតផង។ ស្ថានភាពនៅក្នុងភូមិពេលនោះ គឺអ៊ូអរណាស់ ដែលជាធម្មតាមានផ្ទះត្រឹមតែ១៥០ខ្នង នៅក្នុងភូមិ ហើយគ្រួសារចំណូលថ្មីរាប់រយគ្រួសារ មានសមាជិកគ្រួសារពី បួន ទៅប្រាំមួយនាក់។

### *ខ.៣. ការបោសសម្អាតទាហាន លន់ នល់*

សាក្សីបានរម្លឹកថា ជនភៀសខ្លួនដែលមកពីខេត្តកំពង់ឆ្នាំង និងទីក្រុងភ្នំពេញ ត្រូវបានគេតម្រូវឱ្យសរសេរជីវប្រវត្តិផ្ទាល់ខ្លួនទៅប្រធានភូមិ។ ជីវប្រវត្តិទាំងនេះ ត្រូវបានប្រមូលដោយ **ណាន** ហើយបន្ទាប់មកបានដាក់ជូនទៅ **ស្រ៊ុន** ក៏ប៉ុន្តែ សាក្សី **ឡេវ ឡាំ** បានផ្តល់សក្ខីកម្មថា គាត់មិនដឹងថា ក្រោយមកទៀតមានអ្វី

កើតឡើងចំពោះឯកសារទាំងនោះទេ។ ការបញ្ជាក់ពីសេចក្ដីថ្លែងការណ៍របស់គាត់ ដែលបានធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត សាក្សីបានប្រាប់តុលាការ ពីរបៀបដែលជនភៀសខ្លួន ត្រូវបានបែកចែកគ្នាជាពីរប្រភេទ ដូចជា "កសិករ និង ប្រជាជនមិនធម្មតា ដូចជាទាហាន ដូចជារដ្ឋការ **លន់ នល់** និងនាយទុន"[11]។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំ លោក **ណាន** បានពន្យល់ទៅកាន់សាក្សីថា កសិករគួរត្រូវដាក់ឲ្យរស់នៅដោយឡែក ហើយត្រូវដាក់ឲ្យធ្វើការ។ ទាក់ទងនឹងទាហាន **លន់ នល់** សាក្សីបានរៀបរាប់ថា "គេអត់មានម៉េចសួរទេទាហាន ដឹងតែទាហានគេប្រឆាំងហើយ គេអត់សួរទេ"[12]។ សាក្សីបានប្រាប់តុលាការ ពីវិធីដែលប្រធានភូមិរបស់គាត់បានប្រាប់គាត់អំពីអត្ថិភាពនៃគោលនយោបាយមួយ ក្នុងការបោសសម្អាតគ្រួសារចំនួន១០០ ចេញពីគ្រួសារចំនួន ២០០ ទៅ ៣០០ ដែលបានមកដល់ទីនោះ។ ដើម្បីបញ្ជាក់ពីសេចក្ដីថ្លែងការណ៍ពីមុនរបស់គាត់ ដែលធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត សាក្សីបានប្រាប់តុលាការថា លោក **ស្រ៊ុន** បានបញ្ជាជាការសម្រេចដាច់ខាត ដើម្បីបោសសម្អាតពួកខ្មាំង និងពួកមូលធននិយម។ គាត់បានដឹងរឿងនេះ បន្ទាប់ពីបានស្ដាប់ឮកិច្ចសន្ទនារវាងលោក **ណាន** ជាមួយនឹងប្រធានគណៈស្រុក នៅក្នុងការិយាល័យអង្គភាពជីវពល ។

នៅពេលខ្លះក្នុងខែមិថុនា ឆ្នាំ១៩៧៥ ប្រធានភូមិបានប្រាប់សាក្សី ដើម្បីនាំមនុស្សពេញវ័យមួយក្រុមដែលមានចំនួន២០នាក់ និងក្មេងធ្វើដំណើរដោយដើរ និងរទេះគោទៅការដ្ឋានដែលមានចម្ងាយពីបីទៅបួនគីឡូម៉ែត្រពីភូមិត្រង់សង្កែ។ ប្រធានភូមិបានប្រាប់សាក្សី **ឡេវ ឡាំ** ថា ប្រជាជននៅ "ស្វាយត្រង់" ត្រូវបានហៅថាជា កងជីវពលរបស់ **លន់ នល់** ហើយពួកគេត្រូវបានផ្លាស់ឲ្យនៅកន្លែងថ្មី។ សាក្សីបានរម្លឹកថា នៅពេលដែលពួកគេបានមកដល់ ពួកទាហានស្រុក បានចងដៃប្រជាជន១០នាក់ ចេញពីក្រុម ហើយបានយកពួកគេចេញទៅ។ បន្ទាប់ពីនោះមក គាត់ឮសំឡេងតិចៗ រាប់ចុះពីបីទៅ (បី ពីរ មួយ..) ក៏ប៉ុន្តែ គាត់មិនបានឃើញអ្វីដោយផ្ទាល់នោះទេ។ ទោះជាយ៉ាងណា សាក្សីបានថ្លែងថា គាត់បានឮពីមនុស្សផ្សេងទៀតថា ប្រជាជនត្រូវបានសម្លាប់នឹងដំបង ស្នូលគោ និងឫស្សី។ ប្រហែលជាប្រាំមួយ ឬប្រាំពីរឆ្នាំក្រោយមក នៅពេលដែលសាក្សីបានត្រឡប់ទៅកន្លែង ដែលគាត់បានទុកប្រជាជនចោល គាត់បានឃើញរណ្ដៅចំនួន ២០ ដែលពោរពេញទៅដោយគ្រោងឆ្អឹង។ គាត់បានប៉ាន់ស្មានថា រណ្ដៅមួយ មានលលាដ៍ក្បាលប្រហែលពី ២០ ទៅ ៣០។ មេធាវីការពារក្ដីបានផ្ដល់ការពន្យល់ផ្សេងទៀត អំពីគ្រោងឆ្អឹងនោះ គឺសំដៅទៅលើពន្ធនាគារដំរីស្រុត ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៧៦ ក៏មានទីតាំងក្បែររណ្ដៅគ្រោងឆ្អឹងនោះផងដែរ។ ក៏ប៉ុន្តែ មេធាវីការពារក្ដី **សុន អរុណ** ត្រូវបានរារាំងពីការលើកឡើងពីបញ្ហានេះ ពីព្រោះអង្គជំនុំជម្រះបានសម្រេចថា បញ្ហានេះគឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ (សូមមើលផ្នែកទី ៣.គ) ។

### *ខ.៤. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

ភាពជឿជាក់ និងភាពគួរឲ្យទុកចិត្តរបស់សាក្សីចំពោះព្រឹត្តិការណ៍ ត្រូវបានតវ៉ាព្រមៗគ្នាដោយមេធាវីការពារក្ដី។ នៅដែលពេលសួរដេញដោល សាក្សីបានសារភាពថា គាត់មិនបានឃើញផ្ទាល់ភ្នែកនូវហេតុការណ៍មួយចំនួន ដែលគាត់ផ្ដល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កតឡើយ។ សាក្សី **ឡេវ ឡាំ** ក៏មិនអាចផ្ដល់នូវការពន្យល់ណាមួយ អំពីរបៀបដំណើរនៃការស្វែងរកជីវប្រវត្តិរបស់មន្ត្រី និងទាហាន **លន់ នល់** និងពួកមូលធននិយម ដែលបានសួរក្នុងអំឡុងពេលនៃការសាកសួរដេញផងដែរ។

## គ.	សក្ខីកម្មរបស់សាក្សី ឯក ហេន (អត្តលេខ TCW-164)

លោកស្រី **ឯក ហេន** គឺជាសាក្សីទីបី ដែលផ្ដល់សក្ខីកម្មនៅក្នុងសប្ដាហ៍នេះ។[13] សាក្សីមានតួនាទីជាអតីតសមាជិកនៃអង្គភាពប្រយុទ្ធប្រឆាំងរបស់ស្ត្រី និងជាកម្មករនៅរោងចក្រកាត់ដេរខ្មែរក្រហម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្ដល់សក្ខីកម្មសំខាន់ៗពីវគ្គសិក្សាដែលគាត់បានចូលរួម និងជាកន្លែងដែលសហជនជាប់ចោទមានវត្តមាន។ សាក្សីក៏បានរៀបរាប់ពីរបៀបដែលប្រជាជននៅរោងចក្ររបស់លោកស្រី ត្រូវបានចាប់ខ្លួន ជាពិសេសនោះ អ្នកដែលត្រូវបានចោទប្រកាន់ថា មានការជាប់ទាក់ទងជាមួយនឹងបណ្ដាញភូមិភាគបូព៌ា និងភូមិភាគឧត្តរ។

### *គ.១.	ចលនាមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការជ្រើសរើសឲ្យចូលរួមខ្មែរក្រហម*

សាក្សី **ឯក ហេន** បានចាប់ផ្ដើមផ្ដល់សក្ខីកម្មរបស់លោកស្រី ដោយបានរម្លឹកឡើងវិញពីរបៀបដែលគាត់ត្រូវបានគេជ្រើសរើសឱ្យចូលបម្រើការងារឲ្យខ្មែរក្រហម។ សាក្សីបានរៀបរាប់ថា គាត់បានចូលរួមបម្រើបដិវត្តន៍នៅឆ្នាំ១៩៧៣ នៅខណៈដែលគាត់មានអាយុត្រឹមតែ១៦ឆ្នាំ ប៉ុណ្ណោះ។ នៅចុងឆ្នាំ១៩៧៤ បន្ទាប់ពីធ្វើការដោយដៃយ៉ាងនឿយហត់ ក្នុងការជួយកសាងទំនប់នៅបឹងកក់ សាក្សីបានស្នើសុំឲ្យបញ្ជូនគាត់ទៅអង្គភាពប្រយុទ្ធប្រឆាំងរបស់ស្ត្រី នៅភូមិភាគបូព៌ា។ ដើម្បីពន្យល់ពីការសម្រេចចិត្ត សាក្សីបានថ្លែងថា "អញឈប់លើកទំនប់ហើយ អញទៅធ្វើយុវនារី ងាប់ចោលទៅ"[14]។ អង្គភាពយុទ្ធនារី ត្រូវបានបង្កើតឡើងដោយលោក **សោ ភឹម** ដែលសាក្សី **ឯក ហេន** បានបញ្ជាក់ថា គាត់គឺជាគណៈភូមិភាគ។ ក៏ប៉ុន្តែ ជននៅក្រោមបង្គាប់របស់ **សោ ភឹម** ជាអ្នកបណ្ដុះបណ្ដាល និងគ្រប់គ្រងអង្គភាពនេះ។[15]សាក្សីត្រូវបានបញ្ជាឲ្យធ្វើការនៅក្រុមទី៣ នៃកងធំទី១៣ នៃតំបន់២០៣។ យោងតាមសាក្សី អ្នកស្រីគឺនៅមិនទាន់បានបញ្ចប់វគ្គបណ្ដុះបណ្ដាលយោធារយៈពេលប្រាំមួយខែនៅឡើយ នៅពេលដែលទីក្រុងភ្នំពេញដួលរលំ ដូច្នេះ គាត់មិនដែលបានចូលរួមនៅក្នុងការប្រយុទ្ធប្រឆាំង និងមិនធ្លាប់ទទួលការបណ្ដុះបណ្ដាលពីគោលនយោបាយចាប់ខ្លួនទាហាន **លន់ នល់** អ្វីឡើយ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពយុទ្ធនារី ត្រូវបានរំសាយ និងបានប្រែក្លាយទៅជាកងចល័តវិញ។ សមាជិករបស់អង្គភាពនេះ ត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ រយៈពេលមួយសប្ដាហ៍ ដើម្បីបោសសម្អាតការខូចខាត បន្ទាប់មក ត្រូវបានចាត់តាំងឲ្យទៅខេត្តកំពង់សោម ដើម្បីធ្វើការក្នុងស្រែអំបិល។ បន្ទាប់ពីធ្វើការងារដូចអ្វីដែលសាក្សីបានរៀបរាប់ថា ជាការងារដែលធ្វើដោយដៃយ៉ាងលំបាកខ្លាំង នៅស្រែអំបិល ហើយបន្ទាប់មក សាក្សី **ឯក ហេន** ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅអង្គភាព ក-៩ នៅក្នុងទីក្រុងភ្នំពេញវិញ។

### *គ.២.	បទពិសោធន៍ការងារនៅរោងចក្រកាត់ដេរ ក-៩*

សាក្សី **ឯក ហេន** បានប្រាប់តុលាការថា គាត់បានធ្វើការដេរសម្លៀកបំពាក់នៅរោងចក្រកាត់ដេរមួយឈ្មោះថាអង្គភាព ក-៩ ដែលមានទីតាំងស្ថិតនៅក្នុងទីក្រុងភ្នំពេញ បច្ចុប្បន្នគឺជាផ្សារអូរឫស្សី។ សាក្សីបានផ្ដល់សក្ខីកម្មថា អង្គភាព ក-៩ គឺជាផ្នែកមួយនៃមន្ទីរ៨៧០ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យោងតាមសាក្សី ពេលវេលាធ្វើការ គឺមានរយៈពេលយូរនៅឯអង្គភាព ក-៩ ហើយគាត់បានប្រាប់តុលាការពីរបៀបដែលគាត់ចាប់ផ្ដើមធ្វើការនៅម៉ោង៤ព្រឹក និងបញ្ចប់នៅម៉ោង៩យប់។ សាក្សីបានថ្លែងថា កម្មករនៅអង្គភាព ក-៩ រស់

រានមានជីវិតដោយសារម្ហូបអាហារដែលពួកគេបានដាំដុះ និងចិញ្ចឹមដោយខ្លួនឯង រួមមាន បន្លែ និងសត្វជ្រូក។ សាក្សីបានរម្លឹកយ៉ាងច្បាស់ថា បន្ទាប់ពីដំណើរទស្សនកិច្ចរបស់ជនជាប់ចោទ **ខៀវ សំផន** ទៅកាន់អង្គភាព ក-៩ គុណភាពនៃអាហារដែលផ្ដល់ទៅឱ្យកម្មករនៅអង្គភាព ក-៩ មានភាពប្រសើរឡើង។

### *គ.៣. វគ្គសិក្សានៅបុរីកីឡា*

នៅខណៈពេលដែលធ្វើការនៅក្នុងអង្គភាព ក-៩ សាក្សីបានរម្លឹកថា គាត់បានចូលរួមវគ្គសិក្សាមួយចំនួន ក្នុងអំឡុងពេលដែល ជនជាប់ចោទទាំងពីរ **នួន ជា** និង **ខៀវ សំផន** បានបង្រៀន។ វគ្គសិក្សាបានធ្វើឡើងនៅបុរីកីឡាក្នុងឆ្នាំ១៩៧៦ និងម្ដងទៀតក្នុងឆ្នាំ១៩៧៨។ វគ្គសិក្សានេះត្រូវបានគេស្គាល់ផងដែរថា ជាកិច្ចប្រជុំស្វ័យទិតៀន ហើយសាក្សីបានរម្លឹកថា ជនជាប់ចោទ **ខៀវ សំផន** និង **នួន ជា** បានបង្រៀនកន្លះថ្ងៃម្នាក់ទៅកាន់កម្មាភិបាលប្រហែល ៥០០នាក់។ សាក្សី **ឯក ហេន** បានរម្លឹកថា វគ្គសិក្សានេះបានផ្ដោតទៅលើការនៅបន្តតស៊ូបដិវត្តន៍ ត្រូវមានកិច្ចប្រជុំឲ្យគ្រប់ចំនួន សាមគ្គីភាពជាតិ និងកិច្ចពិភាក្សាអំពីជនជាតិវៀតណាម និង "ជនក្បត់"[16] នៅភូមិភាគឧត្តរ។ យោងតាមសក្ខីកម្មរបស់សាក្សី បន្ទាប់ពីវគ្គសិក្សាត្រូវបានបញ្ចប់ពេលវេលាដែលនៅសល់ពីការបង្រៀននៅថ្ងៃនោះ គឺសម្រាប់ស្វ័យទិតៀន និងទិតៀនអ្នកដទៃ។

### *គ.៤. ការបោសសម្អាតផ្ទៃក្នុង*

ក្នុងអំឡុងពេលនៃការតាំងសំណួរដេញដោលដោយសហព្រះរាជអាជ្ញា សាក្សីបានបញ្ជាក់ពីសេចក្ដីថ្លែងការណ៍ ដែលគាត់បានធ្វើនៅការិយាល័យសហចៅក្រមស៊ើបអង្កេតថា មនុស្សមួយចំនួននៅក្នុងអង្គភាពរបស់គាត់ ត្រូវបានគេចាប់ខ្លួនរួមមានៈ ប្រធានអង្គភាព ក-៩ ដែលមានឈ្មោះថា **កែវ** ដែលគាត់បានឃើញការចាប់ខ្លួននោះដោយផ្ទាល់ភ្នែក។ សាក្សីបាននិយាយថា អ្នកដែលត្រូវចាប់ខ្លួន គឺត្រូវបានគេចោទប្រកាន់ថាជាប់ទាក់ទងជាមួយនឹងបណ្ដាញរបស់ភូមិភាគខាងជើង និងភូមិភាគកើត។ យោងតាមសក្ខីកម្មរបស់សាក្សី ប្រធានអង្គភាព គឺត្រូវបានចាប់ខ្លួនមុនគេ ហើយបន្ទាប់មក អនុប្រធាន ហើយនិងបន្ទាប់ទៀត គឺសមាជិកបក្ស។ សាក្សីបានប្រាប់តុលាការពីហេតុដែលនាំឲ្យមានការចាប់ខ្លួននោះថា ធ្វើឲ្យមានការភ័យខ្លាចយ៉ាងខ្លាំងដល់កម្មករ។ សរុបមក សាក្សី **ឯក ហេន** បានរម្លឹកពីការបាត់ខ្លួនមនុស្សបួននាក់ពីការដ្ឋានរបស់គាត់ ប៉ុន្តែសាក្សីបានផ្ដល់សក្ខីកម្មថា គាត់មិនបានឃើញការចាប់ខ្លួនទាំងអស់នោះដោយផ្ទាល់ទេ។

### *គ.៥. តួនាទីរបស់សហជនជាប់ចោទ និងគោលការណ៍នៃការបោសសម្អាតខ្មាំង*

ទាក់ទងនឹងវគ្គសិក្សាក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ នៅបុរីកីឡា សាក្សីត្រូវបានចោទសួរឲ្យផ្ដល់ព័ត៌មានលម្អិតបន្ថែមពីការបង្រៀនដែលគាត់បានអះអាងថា ត្រូវបានបង្រៀនដោយសហជនជាប់ចោទ **ខៀវ សំផន** និង **នួន ជា**។ សាក្សី **ឯក ហេន** បាននិយាយថា វគ្គសិក្សាក្នុងឆ្នាំ១៩៧៦ បានផ្ដោតទៅលើតវិយាបថការងារ ប្រសិទ្ធភាព និងការរក្សាទុកស្បៀងអាហារ ជាជាងផ្ដោតទៅលើប្រធានបទនយោបាយ។ សាក្សីបានផ្ដល់បទសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតថា វគ្គសិក្សាក្នុងឆ្នាំ១៩៧៨ គឺត្រូវបានដឹកនាំបង្រៀនដោយជនជាប់ចោទ **នួន ជា** ហើយផ្ដោតទៅលើប្រធានបទខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ និងបានណែនាំកម្មករទាំងអស់ឲ្យជៀសវាងពីបណ្ដាញក្បត់។ ការក្បត់ជាតិនៅក្នុងភូមិភាគឧត្តរ និងការចាប់ខ្លួនលោក **កុយ ធួន** ហៅលោក **កុយ ឃួន** ត្រូវបានគេយកមកបង្ហាញនៅក្នុងអំឡុងពេលវគ្គសិក្សា សម្រាប់ជា

ឧទាហរណ៍ ចំពោះខ្មាំងផ្ទៃក្នុង។ សាក្សីក៏បានប្រាប់តុលាការថា គាត់បានឮពីការចាប់ខ្លួនរបស់ **ប៉ង់** ដែលជាអតីតប្រធានមន្ទីរ៨៧០ នៅចុងឆ្នាំ១៩៧៦ ក៏ប៉ុន្តែក្រោយមក សាក្សីបានអះអាងថា គាត់បានឮវាក្នុងអំឡុងពេលនៃកិច្ចប្រជុំលើកទីពីរនៃវគ្គសិក្សាក្នុងឆ្នាំ១៩៧៨។[17]

ទោះបីជាដំបូង សាក្សីបានបញ្ជាក់ទៅកាន់សហព្រះរាជអាជ្ញាថា វគ្គសិក្សានៅក្នុងឆ្នាំ១៩៧៦ គឺបានដឹកនាំដោយជនជាប់ចោទ **ខៀវ សំផន** បន្ទាប់មកជនជាប់ចោទ **នួន ជា** ជាអ្នកបន្ត ក៏ប៉ុន្តែ ដោយមានការសួរដេញដោលរបស់មេធាវីការពារក្តី **អាកធួរ វែកគែន** (Mr. Arthur Vercken) សាក្សីបានអះអាងផ្ទុយពីសម្តីរបស់គាត់ពីមុន និងហាក់ដូចជាបង្ហាញការភាន់ច្រឡំថា តើជនជាប់ចោទមួយណា ដែលបានដឹងនាំកិច្ចប្រជុំ ហើយជាកិច្ចប្រជុំមួយណា ហើយតើជនក្បត់ជាតិត្រូវបានលើកយកនិយាយដែរឬទេក្នុងវគ្គសិក្សា ក្នុងឆ្នាំ១៩៧៦។[18] ចុងក្រោយនោះ សាក្សីបានទទួលស្គាល់ថា ព្រឹត្តិការណ៍នោះបានកើតឡើងយូរមកហើយ រីឯការចងចាំរបស់គាត់បានមានភាពល្អប្រសើរក្នុងអំឡុងឆ្នាំ២០០៨ នៅពេលដែលគាត់បានផ្តល់បទសម្ភាសន៍ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត។ ក៏ប៉ុន្តែ សាក្សីបានអះអាងថា គាត់បានចូលរួមវគ្គសិក្សាចំនួនពីរលើកនៅបុរីកីឡាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វគ្គសិក្សាដំបូង សាក្សីបានថ្លែងថា មិនមានកិច្ចពិភាក្សាអំពីជនក្បត់ទេ។ ប៉ុន្តែ វគ្គសិក្សាទីពីរបាន ពិភាក្សាពីការក្បត់របស់កម្មាភិបាលនៅភូមិភាគឧត្តរ។ សាក្សីក៏បានបញ្ជាក់ថា គាត់បានឃើញជនជាប់ចោទ **ខៀវ សំផន** យ៉ាងហោចណាស់ចំនួនពីរដងនៅអង្គភាព ក-៩ នៅពេលដែលគាត់មកធ្វើការត្រួតពិនិត្យការដ្ឋាន។ សាក្សី **ឯក ហេន** បានរៀបរាប់ពីហេតុការណ៍ដ៏ជាក់លាក់មួយដែលជនជាប់ចោទ **ខៀវ សំផន** បានចុះទៅសួរសុខទុក្ខកម្មករនៅកន្លែងទទួលទានអាហារថ្ងៃត្រង់ ដើម្បីប្រាស្រ័យទាក់ទង និងបានប្រើប្រាស់ស្លាបព្រាជាមួយសាក្សី ក្នុងគោលបំណងភ្លក់ម្ហូបអាហារ ដែលពួកគេកំពុងបរិភោគសម្រាប់ទុកជាគំរូ។

### *គ.៦. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

ចំណុចមួយចំនួននៃសក្ខីកម្មរបស់សាក្សី **ឯក ហេន** គឺមានភាពមិនច្បាស់លាស់ ជាពិសេសទាក់ទងថាតើជនជាប់ចោទមួយណា ដែលបានដឹកនាំវគ្គសិក្សា ដែលសាក្សីបានចូលរួម ហើយប្រធានបទអ្វីដែលត្រូវបានលើកយកមកពិភាក្សា នៅក្នុងវគ្គសិក្សាណាខ្លះ។ ភាពមិនស្របគ្នាដែលបន្ថែមលើការផ្តល់សក្ខីកម្មរបស់អ្នកស្រី គឺត្រូវបានគេបង្ហាញឱ្យដឹងក្រោមការសាកសួរដេញដោល រួមមាន តើគាត់បានដឹងអំពីការចាប់ខ្លួនរបស់ **ប៉ង់** តាមរយៈវគ្គសិក្សាក្នុងឆ្នាំ១៩៧៨ ឬមុនពេលនោះ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីបានទទួលស្គាល់ដោយផ្ទាល់ពីភាពខុសគ្នារវាងសក្ខីកម្មរបស់គាត់ ហើយនិងសេចក្តីថ្លែងការណ៍របស់គាត់ ដែលបានធ្វើនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយបានទទួលស្គាល់ថា ការចងចាំរបស់គាត់ប្រហែលជាបានភ្លេចភ្លាំង ចាប់តាំងពីពេលនោះមក។ លើសពីនេះទៅទៀត សាក្សីបានរក្សានូវភាពស៊ីចង្វាក់គ្នានៃអង្គហេតុមួយចំនួន ដែលគាត់មើលទៅហាក់ដូចជាគួរជឿជាក់ណាស់។

## ឃ. សក្ខីកម្មរបស់សាក្សី ស៊ុម អាឡាត់ (អត្តលេខ TCW-689)

ចាប់ពីថ្ងៃពុធរហូតដល់ថ្ងៃព្រហស្បតិ៍នាសប្តាហ៍នេះ អង្គជំនុំជម្រះ បានស្តាប់នូវសក្ខីកម្មរបស់សាក្សី **ស៊ុម អាឡាត់** ហៅ **ឈុង ឡាត់** ដែលជាអតីតពលបាលត្រីរបស់យោធា **លន់ នល់**។[19] សហព្រះរាជអាជ្ញា និង

ក្រុមការពារក្ដីបានស្នើសុំធ្វើការសួរដេញដោលសាក្សី ក៏ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចថា ដោយសារសហព្រះរាជអាជ្ញាបានស្នើសុំមុន ដូច្នេះ សហព្រះរាជអាជ្ញាគួរតែចាប់ផ្ដើមសួរសំណួរមុន។ សាក្សីបានផ្ដល់សក្ខីកម្មពីការចុះចាញ់របស់ទាហាន **លន់ នល់** នៅខេត្តពោធិ៍សាត់ ការប្រមូលផ្ដុំមន្ត្រីរដ្ឋការ **លន់ នល់** នៅសាលាខេត្តពោធិ៍សាត់ និងការបោសសម្អាតដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ។ សាក្សីក៏បានរៀបរាប់ផងដែរពីការបានចូលរួមក្នុងកិច្ចប្រជុំមួយ ដែលរៀបចំដោយក្រសួងអប់រំក្នុងឆ្នាំ១៩៨០ ដើម្បីប្រមូលទិន្នន័យអំពីអំពើឃោរឃៅរបស់ខ្មែរក្រហម។

### *ឃ.១. តួនាទីក្នុងកងកម្លាំងយោធា លន់ នល់*

សាក្សី **ស៊ុម អាឡាត់** បានចាប់ផ្ដើមផ្ដល់សក្ខីកម្មរបស់គាត់ ដោយបានរម្លឹកឡើងវិញអំពីតួនាទីរបស់គាត់នៅក្នុងយោធា **លន់ នល់** នៅមុនពេលថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥។ បន្ទាប់ពីបានបញ្ចប់ការសិក្សារបស់គាត់ក្នុងឆ្នាំ១៩៧២ រួចមក ដែលពេលនោះគាត់ទើបតែមានអាយុ ១៩ឆ្នាំ សាក្សីបានចូលបម្រើការជាទាហាន **លន់ នល់** នៅខេត្តពោធិ៍សាត់។ បន្ទាប់ពីទទួលបានឋានៈជាពលបាលត្រី គាត់ត្រូវបានគេចាត់តាំងឱ្យទៅធ្វើការនៅការិយាល័យបុគ្គលិកទូទៅប្រចាំខេត្ត។ មេធាវីការពារក្ដី **សុន អរុណ** បានជំទាស់នឹងសាក្សីពីអត្ថិភាពនៃការិយាល័យនោះ និងបានផ្ដល់យោបល់ថា ការិយាល័យបុគ្គលិកទូទៅប្រចាំខេត្ត មានតែមួយគត់នៅទីក្រុងភ្នំពេញប៉ុណ្ណោះ នៅពេលដែលសាក្សីបាននិយាយនោះ។ សាក្សី **ស៊ុម អាឡាត់** បានពន្យល់ថា អភិបាលខេត្តពោធិ៍សាត់ មានតួនាទីពីរ ជាមេដឹកនាំយោធាផង និងមេដឹកនាំប្រជាជនស៊ីវិលផងនៅក្នុងតំបន់នោះ ដូច្នោះហើយ គាត់មានការិយាល័យបុគ្គលិក និងអង្គភាពយោធាដែលរាយការណ៍ជូនគាត់ដោយផ្ទាល់។ នៅក្នុងឆ្នាំ១៩៧៣ សាក្សី **ស៊ុម អាឡាត់** បានរម្លឹកថា គាត់ត្រូវបានប្ដូរទៅសមរភូមិនៅក្រវ៉ាញ ដើម្បីទទួលបន្ទុកប្រតិបត្តិការយោធានៅទីនោះ។ ការរៀបរាប់អំពីសមរភូមិនៅក្រវ៉ាញ ដែលជាសមរភូមិដ៏ក្ដៅមួយនៅក្នុងប្រទេស សាក្សីបានរៀបរាប់ឡើងវិញពីការដឹកនាំជនភៀសខ្លួនមួយពាន់នាក់ ធ្វើដំណើរឆ្ពោះទៅស្រុកលាជ ខេត្តពោធិ៍សាត់ ដើម្បីគេចពីការវាយប្រយុទ្ធគ្នានេះ។

### *ឃ.២. ជ័យជម្នះរបស់ខ្មែរក្រហមក្នុងខេត្តពោធិ៍សាត់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

សាក្សីបានថ្លែងថា នៅខែមេសា ឆ្នាំ១៩៧៥ គាត់ត្រូវបានគេបញ្ជូនឱ្យទៅស្វាយដូនកែវ នៅក្នុងខេត្តពោធិ៍សាត់ ដើម្បីដឹកនាំក្រុមបច្ចេកទេសនៃអង្គភាពកាំភ្លើងធំមួយ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីមានការវាយប្រយុទ្ធគ្នាដ៏ក្ដៅគគុកមួយរួចមក សាក្សី **ស៊ុម អាឡាត់** បានរៀបរាប់ពីវិធីដែលកងកម្លាំងខ្មែរក្រហមបានកាន់កាប់ទីក្រុងពោធិ៍សាត់។ សាក្សីបានរម្លឹកពីការស្ដាប់ឮវិទ្យុជាតិ ដែលបានផ្សព្វផ្សាយដោយតំណាងមេបញ្ជាការបុគ្គលិករបស់ **លន់ នល់** គឺលោកឧត្ដមសេនីយ៍ត្រី **មាស ជុន** ដែលបញ្ជាឲ្យអង្គភាព **លន់ នល់** ទាំងអស់ "ចុះចាញ់ លើកទង់ស និងដាក់អាវុធចុះ"[20]។ បន្ទាប់ពីមានសេចក្ដីប្រកាសនេះរួចមក សាក្សីបានរៀបរាប់ថា ស្ថានភាពនៅពេលនោះ មានភាពសប្បាយរីករាយ និងបានពណ៌នាថា បានឃើញទាហាន **លន់ នល់** និងទាហានខ្មែរក្រហមជាច្រើន នាំគ្នារាំដើម្បីអបអរជាមួយគ្នា។ ក៏ប៉ុន្តែ សាក្សីបានផ្ដល់សក្ខីកម្មថា លុះព្រឹកឡើង អារម្មណ៍ទាំងនោះត្រូវបានផ្លាស់ប្ដូរយ៉ាងខ្លាំង ហើយបានរម្លឹកថា ខណៈពេលដែលពួកគេបានដកថយទៅដល់ផ្លូវជាតិលេខ៥ កងកម្លាំងខ្មែរក្រហមបានបាញ់គ្រាប់កាំភ្លើង ដោយគ្មានការបែកចែករវាងប្រជាជនស៊ីវិល និងទាហាន ដោយ "បាញ់សំដៅទាំងមនុស្ស និងសត្វ"[21]។

បន្ទាប់ពីការគេចពីគ្រាប់កាំភ្លើងមក សាក្សីបានរៀបរាប់ពីការដើរទៅកាន់ស្រុកបាកាន ជាកន្លែងដែលខ្មែរក្រហមប្រមូលផ្តុំកងទ័ព៥០០នាក់ ប្រជាជន និងមន្ត្រីរាជការស៊ីវិលជាច្រើន នៅក្នុងការិយាល័យស្រុកបាកាន ដើម្បីធ្វើការប្រជុំមួយ។ យោងតាមសាក្សី **ស៊ុម អាឡាត់** គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីជូនដំណឹងដល់អ្នកចូលរួមអំពីការអប់រំនយោបាយ និងការជម្លៀសប្រជាជនចេញពីទីក្រុង។ សាក្សីបានរម្លឹកថា គាត់បានលួចចេញពីកិច្ចប្រជុំដោយស្ងាត់ៗ មុនពេលដែលកិច្ចប្រជុំបានបិទបញ្ចប់ ដោយសារតែគាត់បានមានអារម្មណ៍ថា ខ្មែរក្រហមបានមិនជឿទុកចិត្តលើពួកគេឡើយ ក្រោយពេលដែលខ្មែរក្រហមបានបាញ់ទៅលើទាហាននៅផ្លូវជាតិលេខ៥។ បន្ទាប់មក សាក្សីបានធ្វើដំណើរទៅរកគ្រួសាររបស់គាត់នៅឯស្វាយលួង ដោយបានរម្លឹកថា គាត់បានឈប់ដើម្បី "ដោះ" ឯកសណ្ឋានយោធារបស់គាត់ រួចបោះចូលទៅក្នុងទន្លេពោធិ៍សាត់។ គាត់បាននិយាយថា គាត់ធ្វើបែបនេះ ព្រោះប្រសិនបើ ខ្មែរក្រហមរកឃើញថាមានឯកសណ្ឋាននេះនៅក្នុងផ្ទះរបស់គាត់ គាត់នឹងត្រូវស្លាប់។[22]

### *ឃ.៣. កិច្ចប្រជុំនៅសាលាខេត្តពោធិ៍សាត់ សម្រាប់មន្ត្រី លន់ នល់*

នៅ ឬក៏ប្រហែលជាថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ សាក្សីបានធ្វើដំណើរទៅកាន់សាលាក្រុងខេត្តពោធិ៍សាត់ដើម្បីចូលរួមក្នុងការប្រមូលផ្តុំគ្នារបស់អតីតមន្ត្រីរដ្ឋការ **លន់ នល់** ដែលគាត់បានឮដោយពាក្យសម្តី។ នៅពេលដែលមេធាវី **វែកតែន** បានសួរសាក្សីថា ហេតុអ្វីបានជាគាត់ប្រថុយទៅចូលរួមក្នុងកិច្ចប្រជុំនោះ ក្រោយពេលដែលគាត់ចំណាយពេលយ៉ាងយូរ ដើម្បីលាក់បាំងពីអត្តសញ្ញាណរបស់គាត់ សាក្សី **ស៊ុម អាឡាត់** បានឆ្លើយតបយ៉ាងសាមញ្ញថា ការងឿងឆ្ងល់បានធ្វើឲ្យគាត់ហានចូលរួមចង់ដឹង។ កិច្ចប្រជុំនេះ ស្ថិតក្រោមអធិបតីភាពរបស់ **តា សូត្រ** ដែលត្រូវបានគេប្រារព្ធធ្វើឡើងរយៈពេលលើសពីរថ្ងៃ និងបានពិភាក្សាអំពីបញ្ហាទាក់ទងទៅនឹងគោលនយោបាយផ្សះផ្សា ការកសាងប្រទេសជាតិ និងការជឿជាក់ទៅលើអង្គការ។ សាក្សី **ស៊ុម អាឡាត់** បានអះអាងថា នៅក្នុងខេត្តពោធិ៍សាត់ ទាហាន និងរដ្ឋាភិបាលរបស់ **លន់ នល់** បាននៅតែកំពុងតែគ្រប់គ្រងផ្នែកខ្លះៗនៅឡើយ។ សាក្សីបានប្រាប់តុលាការថា មានអតីតយោធា និងមន្ត្រីស៊ីវិលរបស់ **លន់ នល់** ចំនួនប្រហែល៥០០នាក់ បានចូលរួមក្នុងកិច្ចជួបជុំនេះ ហើយប្រហែលជា២០០នាក់ ដែលគាត់បានសម្គាល់ថាជាទាហាន។ គាត់រម្លឹកថា ទាហានមួយចំនួននៅតែស្លៀកឯកសណ្ឋាននៅឡើយ ក៏ប៉ុន្តែទាហានភាគច្រើនបានស្លៀកសម្លៀកបំពាក់ស៊ីវិល។ មេធាវី **កូប៉េ (Koppe)** បានជំទាស់នឹងសក្ខីកម្មរបស់សាក្សីស្តីពីកិច្ចប្រជុំនេះ ដោយបានអះអាងថា សក្ខីកម្មរបស់គាត់ គឺមិនស្របគ្នានឹងសក្ខីកម្មរបស់សាក្សី **អ៊ុង ឆាត** (សូមមើលផ្នែកទី៦ ខាងក្រោម)[23]។ ទោះបីជាសាក្សីបានអះអាងថា បានស្គាល់អ្នកចូលរួមពី១០ ទៅ ២០នាក់ដោយផ្ទាល់ក៏ដោយ ក៏សាក្សីគ្រាន់តែអាចប្រាប់ឈ្មោះទាហានតែម្នាក់ ដែលមានឈ្មោះថា **ឡេង កង** បន្ថែមពីលើឈ្មោះរបស់មិត្តភក្តិតាំងពីក្មេងចំនួនពីរនាក់របស់គាត់។ នៅពេលមានសំណួរសួរថា តើលោក **ឡេង កង** នៅរស់ដែរឬទេ សាក្សីបានឆ្លើយថា "គាត់ (**ឡេង កង**) បានទៅចូលរួមវគ្គអប់រំរៀនសូត្រនៅឯទួលពោធិ៍ជ្រៃបាត់ទៅហើយ។ សូមបញ្ចាក់ចម្លើយរបស់ខ្ញុំប៉ុណ្ណឹង"[24]។

យោងតាមសក្ខីកម្មរបស់សាក្សី មន្ត្រីរដ្ឋការ **លន់ នល់** ដែលមានវត្តមានក្នុងកិច្ចប្រជុំនោះ ត្រូវបានប្រាប់ថា ពួកគេនឹងត្រូវបញ្ជូនទៅទួលពោធិ៍ជ្រៃ ដើម្បីបង្រួបបង្រួមជាមួយនឹងអង្គការ។ សាក្សី **ស៊ុម អាឡាត់** បានរៀបរាប់ពីបរិយាកាសពោរពេញដោយក្តីរីករាយ។ ហើយខ្លួនគាត់ផ្ទាល់ក៏មានអារម្មណ៍ថា ធុញទ្រាន់នឹង

សង្គ្រាម និងគ្រាន់តែចង់បានសន្តិភាពប៉ុណ្ណោះ។ គាត់បាននិយាយថា "ខ្ញុំនៅតាំងអារម្មណ៍ថា នឹងអាចឈានដល់ព្រឹត្តិការណ៍ដែលយើងកាត់ស្មានមិនបានទេ...នៅតែសុទិដ្ឋិនិយមថា ខ្មែរនឹងខ្មែរ"[25]។ ក្រោយពេលកិច្ចប្រជុំបានបញ្ចប់ សាក្សីបានរម្លឹកថា មានរថយន្តចំនួនប្រហែលពី១៣ ទៅ១៥គ្រឿង បានដឹកមន្ត្រីទាំងអស់នោះចេញពីកន្លែងប្រជុំនោះ។ គាត់បានប៉ាន់ស្មានថា រថយន្តមួយគ្រឿងប្រហែលជាបានដឹកមនុស្សពី៥០ ទៅ៦០នាក់។ យោងតាមសក្ខីកម្មរបស់សាក្សី **ស៊ុម អាឡាត់** មនុស្សទាំងនោះមានចិត្តសប្បាយរីករាយណាស់ចង់ទៅជួបអង្គការ ដែលរថយន្តដឹកមនុស្សទាំងអស់នោះ បានដាក់មនុស្សពេញយ៉ាងឆាប់រហ័ស ហើយគាត់មិនអាចឡើងលើរថយន្តឲ្យទាន់គេបាននោះ។ មានមនុស្សចំនួនប្រហែល៦០នាក់ផ្សេងទៀតនៅសល់ តាមដែលគាត់បានចាំថា គាត់បានដេញតាមរថយន្តទាំងនោះ ក៏ប៉ុន្តែ ត្រូវបានគេប្រាប់ឱ្យនៅរង់ចាំរថយន្តជើងក្រោយ។ ទោះបីជាយ៉ាងនេះក្តី ពេលពីរម៉ោងក្រោយមក រថយន្តទាំងនោះនៅតែមិនទាន់ត្រឡប់មកវិញ ដូច្នេះហើយសាក្សីក៏បានវិលត្រឡប់ផ្ទះទៅរកគ្រួសាររបស់គាត់វិញ។

### *ឃ.៤. ការបោសសម្អាតនៅទួលពោធិ៍ជ្រៃ*

សាក្សី **ស៊ុម អាឡាត់** បានផ្តល់សក្ខីកម្មថា គាត់មិនបានឃើញមនុស្សត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃដោយផ្ទាល់ភ្នែករបស់គាត់នោះទេ ក៏ប៉ុន្តែ គាត់បានឮពីរឿងនេះ ប្រហែលជាបីថ្ងៃក្រោយ នៅពេលដែលមិត្តភក្តិតាំងពីក្មេងទាំងពីរនាក់របស់គាត់ឈ្មោះ **ផាត់** និងឈ្មោះ **ដួង** ដែលបានឡើងជិះរថយន្តនោះ បានប្រាប់គាត់ពីការរត់គេចខ្លួនរបស់ពួកគេ។ យោងតាមសក្ខីកម្មរបស់សាក្សី មិត្តភក្តិរបស់គាត់បានប្រាប់គាត់ថា នៅចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីទួលពោធិ៍ជ្រៃ ខ្មែរក្រហមបានចងទាហានទាំងនោះ ដោយធ្វើពុតថា គេតម្រូវឱ្យធ្វើបែបនេះ ដើម្បីជួបជាមួយនឹងអង្គការ ហើយក៏បានសម្លាប់ពួកគេតែម្តង។ បន្ទាប់ពីនិយាយជាមួយមិត្តរបស់គាត់ពីរនាក់ពីការរត់គេចខ្លួនរបស់ពួកគេមក សាក្សីមិនដែលបានឃើញពួកគេទាំងពីរ ឬអ្នកដទៃទៀត ដែលបានឡើងជិះរថយន្តម្តងទៀតឡើយ។ ក្រោយមក គាត់បានឮពីអ្នកភូមិថា មិត្តភក្តិរបស់គាត់ត្រូវបានចាប់ខ្លួនដោយខ្មែរក្រហម និងបានសម្លាប់ចោលទៅហើយ។ សាក្សីក៏បានបញ្ជាក់ថា គាត់បានឃើញដោយផ្ទាល់នូវម៉ាស៊ីនឈូសដី ដែលបានធ្វើដំណើរតម្រង់ទៅតំបន់នោះ ដែលគាត់បានជឿជាក់ថា គឺត្រូវបានបញ្ជូនឲ្យទៅកប់សាកសពទាហានទាំងនោះ។

### *ឃ.៥. ការចូលរួមរបស់សាក្សីក្នុងការបង្ហាញភស្តុតាងឲ្យក្រសួងអប់រំក្នុងឆ្នាំ១៩៨០*

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ សាក្សីបានបម្រើការងារជាគ្រូបង្រៀនម្នាក់នៅក្នុងក្រសួងអប់រំ។ នៅក្នុងឆ្នាំ១៩៨០ គាត់ត្រូវបានកោះហៅដោយរាជរដ្ឋាភិបាល ឲ្យមកកាន់ទីក្រុងភ្នំពេញជាមួយនឹងគ្រូបង្រៀនប្រាំនាក់ផ្សេងទៀត ដែលបានឃើញឧក្រិដ្ឋកម្មក្នុងខេត្តពោធិ៍សាត់។ ដោយធ្វើរបួមគ្នាក្រុមនេះបានរៀនសូត្រពីរបៀបចង់ក្រងប្រមូលផ្តុំឯកសារ និងការធ្វើបទបង្ហាញភស្តុតាងពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ដែលត្រូវបានចោទប្រកាន់ថាបានកើតមានឡើងនៅក្នុងខេត្តពោធិ៍សាត់។ សាក្សី **ស៊ុម អាឡាត់** បានប្រាប់តុលាការថា គាត់ និងសមាជិកដទៃទៀត បានធ្វើការប៉ាន់ស្មានថា មានមនុស្សចំនួនប្រហែល ២០០០នាក់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ដោយផ្អែកលើសក្ខីកម្មរបស់គាត់ និងកិច្ចសម្ភាសន៍ដែលគាត់បានធ្វើឡើងជាមួយនឹងមេឃុំ **វាយ ហ្លួង** ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងកិច្ចសម្ភាសន៍ជាមួយ **សេង ជួន** និងអ្នកផ្សេងៗទៀត បន្ទាប់ពីការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យ។

### ឃ.៦. *ឥរិយាបថ និងទំនួលខុសត្រូវរបស់សាក្សី*

សាក្សី **ស៊ុម អាឡាត់** បានបង្ហាញឲ្យឃើញពីការរក្សានូវឥរិយាបថនឹងធឹង នៅពេលឆ្លើយនឹងសំណួរនានា ថ្វីបើត្រូវបានសួរដេញដោលដោយក្រុមមេធាវីការពារក្ដីទាំងពីរក៏ដោយ។ ទិដ្ឋភាពជាច្រើននៃសក្ខីកម្មរបស់សាក្សី មានភាពផ្ទុយគ្នានឹងសក្ខីកម្មរបស់សាក្សី **អ៊ុង ឆាត** ដែលបានធ្វើនៅចំពោះមុខអង្គជំនុំជម្រះ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣។ ដូចដែលមេធាវី **វិចទ័រ កូប៉េ** បានធ្វើការចង្អុលបង្ហាញ ក្នុងអំឡុងពេលនៃការសួរដេញដោលរបស់គាត់ ដែលថាសក្ខីកម្មរបស់សាក្សី **អ៊ុង ឆាត** មានភាពខុសគ្នាពីសក្ខីកម្មរបស់សាក្សីទាក់ទិននឹងអង្គហេតុជាច្រើន រួមមាន៖ ចំនួនរថយន្តដែលដឹកជញ្ជូនទាហាន **លន់ នល់** ទីតាំងនៃកិច្ចប្រជុំ និងថាតើមេដឹកនាំរបស់អតីតមេបញ្ជាការ **លន់ នល់** ពីររូបនៅទួលពោធិ៍ជ្រៃ លោក **ពិល** និងលោក **រឿន** ត្រូវបានគេយកទៅដាក់នៅលើស្នឹងនៅច្រកទ្វារនៃកន្លែងសម្លាប់ដែរ ឬទេ។[26] ទោះបីជាព្រឹត្តិការណ៍នានានៃសក្ខីកម្មរបស់សាក្សី **អ៊ុង ឆាត** ត្រូវបានលើកបង្ហាញយ៉ាងណាក៏ដោយ ក៏សាក្សី **ស៊ុម អាឡាត់** បានមានជំហរទៅលើសេចក្ដីថ្លែងការណ៍ភាគច្រើន ដែលគាត់បានធ្វើឡើងក្នុងបទសម្ភាសន៍របស់គាត់ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងឆ្នាំ២០០៨។ ទោះបីជាយ៉ាងនេះក្ដី មេធាវីការពារក្ដីក៏បានបង្ហាញឱ្យដឹងពីភាពមិនស៊ីចង្វាក់គ្នាមួយចំនួនតូចរវាងសក្ខីកម្មរបស់គាត់ និងសេចក្ដីថ្លែងការណ៍របស់គាត់ដែលបានធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត។ បញ្ហាមួយចំនួនបន្ថែមទៀតដែលអ្នកឃ្លាំមើលសវនាការបានកត់សម្គាល់នោះ គឺសាក្សីរូបនេះមិនអាចប្រាប់ឈ្មោះ ឬហ៊ានះមនុស្សច្រើនជាងបីនាក់ ដែលបានមានវត្តមាននៅក្នុងកិច្ចប្រជុំដែលសាក្សីបានប៉ាន់ស្មានថា មានចំនួនមនុស្ស៥០០នាក់បានចូលរួម។

## ផ្នែកទី៣ ៖ បញ្ហាច្បាប់ និងនីតិវិធី

នាសប្ដាហ៍នេះ បញ្ហាច្បាប់ និងនីតិវិធី បានផ្ដោតសំខាន់លើភាពពាក់ព័ន្ធនឹងការសួរសំណួរជាច្រើន ការប្រើប្រាស់ឧបមាវិធី (ការទាយស្មាន) និងការសួរសំណួរដែលនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ ការកម្រិតតួនាទីរបស់មេធាវីប្រឹក្សា ក៏ត្រូវបានលើកឡើងជាថ្មីម្ដងទៀត នៅក្នុងសប្ដាហ៍នេះ ដោយសារតែអង្គជនុំជម្រះបានណែនាំដល់មេធាវីប្រឹក្សាឲ្យសាក្សី **ពេជ្រ ជឹម** ធ្វើការពិគ្រោះយោបល់ជាមួយនឹងសាក្សីនៅពេលណាដែលគាត់ស្វែងរកការប្រឹក្សាទាក់ទងនឹងសំណួរ ដែលជះឥទ្ធិពលលើការដាក់ពិរុទ្ធភាពមកលើខ្លួនឯងតែប៉ុណ្ណោះ។[27] អង្គជំនុំជម្រះ ក៏បានអនុញ្ញាតស្របតាមសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការទទួលយកនូវភស្ដុតាងថ្មី ទោះបីជាលក្ខខណ្ឌនៃវិធានផ្ទៃក្នុង ៨៧.៤ មិនត្រូវបានបំពេញតាមក៏ដោយ ដែលប្រការនេះបានធ្វើឲ្យកើតមានឡើងនូវបញ្ហានៃភាពស្មើគ្នារវាងភាគីទាំងអស់។[28]

### ក. សិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពមកលើខ្លួនឯង និងតួនាទីរបស់មេធាវីប្រឹក្សា

សាក្សី **ពេជ្រ ជឹម** បានព្យាយាមប្រើប្រាស់សិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពមកលើខ្លួនឯង ចំនួនពីរលើក ក្នុងពេលផ្ដល់សក្ខីកម្មរបស់គាត់ទាំងស្រុង។ លើកទីមួយ មេធាវី **កូប៉េ** បានចោទសួរសាក្សីថា តើគាត់ធ្លាប់បានចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ ឬសម្លាប់ខ្មាំងដែរឬទេ។ នៅមុនពេលដែលសាក្សីបានឆ្លើយនូវសំណួរនេះ មេធាវីប្រឹក្សា គឺលោក **ម៉ម រិទ្ធា** បានធ្វើអន្ដរាគមន៍ ដោយបានអះអាងថា សំណួរនេះអាចនាំឲ្យសាក្សីឆ្លើយដាក់ពិរុទ្ធភាពមកលើខ្លួនឯងបាន។ លោកប្រធានអង្គជំនុំជម្រះ បានក្រើនរម្លឹកដល់មេធាវីប្រឹក្សាឲ្យធ្វើ

ការពិគ្រោះយោបល់ជាមួយសាក្សីជាមុនសិន មុនពេលធ្វើការឆ្លើយតបក្នុងនាមសាក្សី ដោយបានបន្ថែមថា គាត់មិនមានតួនាទីជាមេធាវីការពារក្ដីទេនៅទីនោះ។ ជាថ្មីម្ដងទៀត នៅក្នុងវគ្គដដែលនេះ មេធាវី **កូប៉េ** បានចោទសួរទៅកាន់សាក្សី អំពីភាពខុសគ្នារវាងការអប់រំរៀនសូត្រឡើងវិញចំពោះប្រជាជនស៊ីវិល និងទាហាន **លន់ នល់** ក៏ដូចជា របៀបដែលសាក្សីបានដឹងពីភាពខុសគ្នានេះ។ សាក្សីបានឆ្លើយតបថា គាត់មិនអាចឆ្លើយតបនឹងសំណួរទាំងនេះបានទេ ហើយថែមទាំងបានសម្លឹងទៅរកមេធាវីប្រឹក្សារបស់គាត់ដើម្បីឲ្យជួយទៀតផងដែរ។ លោកប្រធានអង្គជំនុំជម្រះបានរម្លឹកឡើងវិញថា មេធាវីប្រឹក្សាមិនអាចជួយសាក្សី ក្នុងការឆ្លើយតបទៅនឹងសំណួរបាននោះទេ ក៏ប៉ុន្ដែ មានភារកិច្ចផ្ដល់យោបល់ដល់សាក្សី អំពីរបៀបនៃការឆ្លើយតបនឹងសំណួរដើម្បីជៀសវាងការឆ្លើយដាក់ពិរុទ្ធភាពមកលើខ្លួនឯង។

## ខ. ការឆ្លើយឧបមា (ការទាយស្មាន) របស់សាក្សី

នាសប្ដាហ៍នេះ មានការជំទាស់ជាច្រើនត្រូវបានលើកឡើង ទាក់ទងទៅនឹងការឆ្លើយឧបមាពីសាក្សីជាពិសេស ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់សាក្សី **ពេជ្រ ជឹម** និងសាក្សី **ឡេវ ឡាំ**។ ក្នុងអំឡុងពេលនៃការសាកសួរដេញដោលសាក្សី **ពេជ្រ ជឹម** មេធាវីការពារក្ដី **កូប៉េ** បានព្យាយាម "សួរទៅកាន់សាក្សី" ចំនួនពីរលើកដោយលើកឡើងថា បុគ្គលិកយោធាគ្រាន់តែត្រូវបានបញ្ជូនទៅអប់រំរៀនសូត្រឡើងវិញ ហើយក្រោយមក ត្រូវបានបញ្ជូនត្រឡប់មកផ្ទះរបស់ពួកគេវិញ។ សហព្រះរាជអាជ្ញា **រេយ៍ន័រ (Raynor)** បានជំទាស់ទៅនឹងសំណួរ ដោយផ្អែកលើមូលដ្ឋានថា ពួកគេបានផ្អែកលើការឆ្លើយឧបមា និងមិនបានផ្អែកលើភស្តុតាងអ្វីឡើយ។ ទោះបីជាការតវ៉ាប្រឆាំងរបស់មេធាវី **កូប៉េ** ដែលថា សហព្រះរាជអាជ្ញា **រេយ៍ន័រ** បានប្រើវិធីសាស្ត្រជាក់លាក់ដូចគ្នា ក្នុងអំឡុងពេលនៃការសួរដេញដោលរបស់គាត់ទៅលើសាក្សី **សូ សុជាតិ** ក៏ដោយ ក៏លោកប្រធាន **និល ណុន** បានស្នើឲ្យមេធាវី **កូប៉េ** ចាប់ផ្ដើមឆ្លងចូលសំណួរថ្មីបន្ត។ ការជំទាស់បន្ថែមដទៃទៀត ត្រូវបានលើកឡើង ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់សាក្សី **ឡេវ ឡាំ**។ ទោះបីជាយ៉ាងនេះក្ដី លើកនេះការជំទាស់ទាំងនេះ ត្រូវបានធ្វើឡើងទៅលើការប្រើប្រាស់ឃ្លាឧបមារបស់សាក្សី ដូចជាការប្រើប្រាស់ឃ្លា "វាទំនងជា" នៅពេលដែលសាក្សីបានរៀបរាប់ពីវិធីសាស្ត្រនៃការសម្លាប់មនុស្ស ដែលសាក្សីបាននាំទៅឲ្យកងទ័ពគណៈស្រុក។[29] លោកប្រធានអង្គជំនុំជម្រះ បានព្រមានដល់សាក្សី បន្ទាប់ពីមេធាវីការពារក្ដី **កូប៉េ** បានស្នើសុំលោកប្រធាន ឲ្យហាមឃាត់សាក្សីមិនឲ្យឆ្លើយឧបមាក្នុងវិធីបែបនេះ។ នៅថ្ងៃអង្គារ អង្គជំនុំជម្រះក៏បានយល់ស្របផងដែរនឹងការជំទាស់ពីសំណាក់សហព្រះរាជអាជ្ញា ទៅនឹងសំណួរមួយរបស់មេធាវីការពារក្ដី **កូប៉េ** ដែលបានស្នើសុំសាក្សី ឲ្យធ្វើការផ្ដល់មតិយោបល់ ថាតើមនុស្សដែលបានទទួលស្គាល់ថា ជាទាហាន **លន់ នល់** នៅក្នុងប្រវត្តិរូបរបស់គេជួប "សំណាងអាក្រក់" ដែរឬទេ។[30]

## គ. ការសួរសំណួរដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១

ពេញមួយសប្ដាហ៍នេះ ទាំងភាគី និងទាំងអង្គជំនុំជម្រះ បានសម្ដែងពីការតាំងចិត្តក្នុងការរក្សាការសួរសំណួរដេញដោលឲ្យស្ថិតក្នុងវិសាលភាពនៃការសំណុំរឿង០០២/០១ តែប៉ុណ្ណោះ។ ជាឧទាហរណ៍មួយដែលត្រូវបានគេមើលឃើញ នៅពេលដែលមេធាវីការពារក្ដី **សុន អរុណ** បានព្យាយាមសាកសួរដេញដោលសាក្សី **ឡេវ ឡាំ** អំពីពន្ធនាគារ **ដំរីស្រុត** ដែលទីតាំងនោះនៅក្បែររណ្ដៅផ្នូរ ដែលសាក្សីបានជួបប្រទះនៅចន្លោះឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨២។ លោកប្រធានអង្គជំនុំជម្រះ បានយល់ស្របចំពោះការជំទាស់របស់សហ

ព្រះរាជអាជ្ញា ដោយបានហាមឃាត់មេធាវីការពារក្តី **សុន អរុណ** ឲ្យគោរពតាមកិច្ចដំណើរការនីតិវិធីនៃការសួរសំណួរដេញដោលរបស់គាត់ ទោះបីជាគាត់បានតវ៉ាថា ពន្ធនាគារនោះត្រូវបានសាក្សីដាក់ចូលទៅក្នុងសេចក្តីថ្លែងការណ៍របស់សាក្សី ដែលធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយក៏បានសំដៅទៅនឹងសំណួរក្នុងអំឡុងពេលសួរដេញដោលមុនៗដោយភាគីទាំងអស់ក៏ដោយ។[31] លោកប្រធានអង្គជំនុំជម្រះ ក៏បានការពារទុកជាមុនដោយព្រមានដល់ភាគីទាំងអស់ នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា ភាគីបានងាកចេញពីវិសាលភាពនៃសំណុំរឿង០០២/០១នោះ ទោះបីជាត្រូវបញ្ចៀសរាល់ការសួរសំណួរបច្ចេកទេសនៅក្នុងវិសាលភាពនៃសវនាការផ្នែកទីមួយនេះក៏ដោយ ក៏ប៉ុន្តែ មិនត្រូវស្ថិតនៅក្នុងព្រំដែននៃប្រធានបទដែលសាក្សីត្រូវបានកោះហៅមក។ ជាពិសេស ប្រការបែបនេះ បានស្តែងឲ្យឃើញនៅពេលដែលលោកប្រធានអង្គជំនុំជម្រះបានកាត់សំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី **ស៊ិន សុវន** ចំនួនពីរលើក ហើយបានណែនាំដល់ឲ្យសាក្សី **ឯក ហេន** មិនឱ្យឆ្លើយតបទៅនឹងសំណួរ ទាក់ទងទៅនឹងការបណ្តុះបណ្តាលយោធា ឬការរៀបការដោយបង្ខំរបស់គាត់។ [32] លោកប្រធានអង្គជំនុំជម្រះ ក៏បានយល់ស្របនឹងការជំទាស់បន្ថែមមួយរបស់មេធាវី **កូប៉េ** ពាក់ព័ន្ធទៅនឹងការព្យាយាមរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ចិត វណ្ណលី** ក្នុងការសាកសួរទៅកាន់សាក្សី **ស៊ុម អាឡាត់** ស្តីពីការរៀបការដោយបង្ខំ។

## ឃ. សំណួរនាំមុខ

ដោយធ្វើការបញ្ជាក់ពីគោលបំណងរបស់គាត់ ក្នុងការត្រៀមខ្លួនសម្រាប់ការធ្វើបណ្តឹងឧទ្ធរណ៍នាពេលអនាគតរបស់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** មេធាវី **កូប៉េ** បានធ្វើការជំទាស់យ៉ាងច្រើនទាក់ទងនឹងសំណួរនាំមុខ និងសំណួរច្រំដែល ក្នុងសប្តាហ៍នេះ។ ការជំទាស់សំខាន់ៗដែលលើកឡើងដោយមេធាវី **កូប៉េ** មានគោលដៅសំដៅលើការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដោយសហព្រះរាជអាជ្ញា ធ្វើជាមូលដ្ឋាននៃការសួរសំណួរដេញដោល។ មេធាវី **កូប៉េ** បានតវ៉ាថា ប្រការបែបនេះ គឺជាការបញ្ជាក់អះអាងយ៉ាងសំខាន់ ពីភាពត្រឹមត្រូវនៃខ្លឹមសាររបស់ឯកសារ។[33] ជាការឆ្លើយតបសហព្រះរាជអាជ្ញាបានតវ៉ាថា ជាដំបូង សហព្រះរាជអាជ្ញាបានប្រើប្រាស់សំណួរបើកជាមូលដ្ឋានជាមុនសិនមុននឹងយោងទៅលើសេចក្តីថ្លែងការណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានយល់ស្របនឹងការជំទាស់ទាំងនោះទេ ដោយបានរម្លឹកដល់មេធាវីការពារក្តីថា ការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើជាមូលដ្ឋាននៃការសួរសំណួរ គឺការអនុវត្តដែលអាចបានទទួលយកបាន នៅក្នុងអង្គជំនុំជម្រះសាលាដំបូងនេះតាំងពីពីរឆ្នាំមុនមកម្ល៉េះ។ បញ្ហាសំណួរនាំមុខត្រូវបានលើកឡើងសាជាថ្មីម្តងទៀត ក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី **ឯក ហេន** ពីសំណាក់មេធាវី **វែកគែន**។ មេធាវី **វែកគែន** បានព្យាយាមបញ្ជាក់ពីកាលបរិច្ឆេទ ដែលសាក្សីបានយោង ក៏ប៉ុន្តែ ត្រូវបានកាត់ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **គ្រីនស្ទីន ម៉ាទីណូ (Martinneau)** ដោយបានជំទាស់ថាការយោងរបស់មេធាវី **វែកគែន** ចេញពីសេចក្តីថ្លែងការណ៍មុនៗរបស់សាក្សី គឺមានលក្ខណៈ "នាំមុខខ្លាំងពេក"។ លោកប្រធានអង្គជំនុំជម្រះ មិនបានបញ្ជាក់ថា តើសំណួររបស់មេធាវីការពារក្តី មានលក្ខណៈជាសំណួរនាំមុខដែរ ឬអត់។ ក៏ប៉ុន្តែ បានស្នើសុំឲ្យមេធាវី **វែកគែន** ប្តូរទៅប្រធានបទផ្សេងៗទៀត ដោយសារតែ "អង្គជំនុំជម្រះបានឮនូវការតាំងសំណួរបែបនេះ..."[34]។

### ង. សំណួរច្រំដែល

កាលពីថ្ងៃអង្គារ សហព្រះរាជអាជ្ញា **លីសាក់ (Lysak)** ក៏បានជំទាស់នឹងសំណួរច្រំដែលរបស់មេធាវី **កូប៉េ** ផងដែរ នៅពេលដែលមេធាវីការពារក្ដីបានព្យាយាមធ្វើឲ្យសក្ខីកម្មរបស់សាក្សីមិនឲ្យគួរទុកចិត្ត ដែលថា អតីតទាហាន និងមន្ត្រីរដ្ឋការ **លន់ នល់** ត្រូវបានជ្រើសរើស ជួបប្រជុំគ្នា និង "បានប្រើល្បិច" ដើម្បីឲ្យពួកគេចាកចេញពីលំនៅដ្ឋាន។[35] សហព្រះរាជអាជ្ញា **លីសាក់** បានលើកទឡ្ហីករណ៍ថា វិធីសាស្ត្រនៃការសួរសំណួររបស់មេធាវី **កូប៉េ** គឺមានលក្ខណៈច្រំដែល និងវិលវល់ចុះឡើង។ មេធាវី **កូប៉េ** បានតវ៉ាដោយបន្ថែមថា តាមពិតទៅ រាល់សំណួររបស់គាត់ទាំងអស់ គឺមានភាពខុសគ្នា។ លោកប្រធានអង្គជំនុំជម្រះ បានគាំទ្រការជំទាស់របស់សហព្រះរាជអាជ្ញា ហើយបានលើកបង្ហាញថា អង្គជំនុំជម្រះបានយល់រួចទៅហើយពីអ្វីដែលមេធាវី **កូប៉េ** កំពុងតែចោទសួរនោះ។ លើសពីនេះទៅទៀត លោកប្រធានអង្គជំនុំជម្រះបានបន្ថែមទៀតថា តម្លៃសាកល្បងនៃសក្ខីកម្មរបស់សាក្សី គឺជាបញ្ហានៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។

### ច. ការជំទាស់នឹងមេធាវីការពារក្ដី អំពីទឡ្ហីករណ៍ទាក់ទងនឹងសំណួរដេញដោល

នៅថ្ងៃអង្គារ ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់សាក្សី **ឡេវ ឡាំ** មេធាវីការពារក្ដី **កូប៉េ** បានសួរដេញដោលសាក្សីតែម្ដង ថាតើសក្ខីកម្មរបស់សាក្សីស្ដីពីការបោសសម្អាតអតីតមន្ត្រី **លន់ នល់** គឺគ្រាន់តែជាការស្រមើលស្រមៃរបស់គាត់ ឬក៏យ៉ាងណា។ ការលើកឡើងបែបនេះ បានជំរុញឱ្យមានការជំទាស់យ៉ាងឆាប់រហ័សពីសហព្រះរាជអាជ្ញា ដោយបានអះអាងថា មេធាវី **កូប៉េ** បានកំពុងបិទបាំងពីទឡ្ហីករណ៍របស់គាត់ដែលថា ការសម្លាប់មិនដែលកើតមានឡើងឡើយទាក់ទងនឹងសំណួរនេះ។ ដោយធ្វើការរៀបរាប់បន្ថែមអំពីការជំទាស់នេះ សហព្រះរាជអាជ្ញា **លីសាក់** បានថ្លែងថា មេធាវី **កូប៉េ** គួរតែកំណត់សំណួរដេញដោលរបស់គាត់ឲ្យមានភាពជាក់លាក់ទៅនឹងសក្ខីកម្មរបស់សាក្សី។ ការជំទាស់នេះ ត្រូវបានគាំទ្រដោយអង្គជំនុំជម្រះ ទោះបីជាមេធាវី **កូប៉េ** បានតវ៉ាថា គាត់កំពុងតែព្យាយាមបញ្ជាក់ឲ្យកាន់តែច្បាស់ ពីអ្វីដែលសហព្រះរាជអាជ្ញាកំពុងធ្វើការជំទាស់នោះ មានដូចជា ថាតើមានការបោសសម្អាតមន្ត្រីរដ្ឋការ **លន់ នល់** បានកើតឡើងពិតប្រាកដ ដែរឬអត់។

### ឆ. ការស្នើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់បញ្ចូលភស្តុតាងថ្មី ដោយអនុលោមតាម វិធានផ្ទៃក្នុងលេខ ៨៧.៤

នៅពេលចាប់ផ្ដើមនៃការផ្ដល់សក្ខីកម្មរបស់សាក្សី **ឯក ហេន** សហព្រះរាជអាជ្ញា បានដាក់សំណើមួយដើម្បីដាក់បញ្ចូលភស្តុតាងថ្មី ដោយអនុលោមតាមវិធានផ្ទៃក្នុងលេខ ៨៧.៤។[36] សហព្រះរាជាអាជ្ញា បានស្នើសុំប្រើប្រាស់រូបថតមួយចំនួន និងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស២១ ដែលមាន ៣៧០ទំព័រ ក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី **ឯក ហេន**។ ក្រុមមេធាវីការពារក្ដី បានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដោយផ្អែកលើមូលដ្ឋានចំនួនប្រាំ៖ ក) ការិយាល័យសហព្រះរាជអាជ្ញា បានបរាជ័យក្នុងការដាក់បញ្ចូលឯកសារឲ្យទាន់ពេលវេលា[37] ខ) សាក្សីមិនត្រូវបានគេបង្ហាញពីរូបថត នៅពេលដែលគាត់បានផ្ដល់បទសម្ភាសន៍ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ២០១៣ គ) រូបថតទាំងនោះ បានដាក់បញ្ចូលទៅក្នុងសំណុំឯកសារនៃសំណុំរឿង០០១ ដោយបានធ្វើការបញ្ជាក់ថា ឯកសារទាំងនោះអាចរកបានជាយូរណាស់

មកហើយសម្រាប់សហព្រះរាជអាជ្ញា ឃ) រូបថតទាំងអស់នោះ គឺយកមកពីមន្ទីរស-២១ និងស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និង ង) សហព្រះរាជអាជ្ញាបានដាក់សេចក្ដីស្នើសុំដោយផ្ទាល់មាត់ ជាជាងការស្នើសុំជាលាយលក្ខណ៍អក្សរ។ ដោយបានធ្វើការពន្យល់ពីការដាក់សារណាយឺតយ៉ាវ សហព្រះរាជអាជ្ញាបានថ្លែងថា សក្ខីកម្មរបស់សាក្សី **ឯក ហេន** ត្រូវបានធ្វើឡើងមុនពេលកំណត់ដែលបានគ្រោងទុក ដូច្នេះសហព្រះរាជអាជ្ញាមិនអាចធ្វើការស្នើសុំដាក់បញ្ចូលនូវឯកសារទាំងនេះ កាលពីពេលកន្លងទៅឡើយ។[38]

យោងតាមការប្រឹក្សារវាងចៅក្រមអង្គជំនុំជម្រះ ចៅក្រម **ខាតរ៉ាយថ៍** (Cartwrigh) បានបញ្ជាក់ថាឯកសារមួយចំនួន ត្រូវបានគេដាក់បញ្ចូលទៅក្នុងភស្តុតាងរួចទៅហើយ ហើយបញ្ហាចោទនោះ គឺទាក់ទងនឹងរូបថតពីរសន្លឹក ដែលមិនធ្លាប់បានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះឡើយ។[39] ទោះបីជាមេធាវីការពារក្ដីមិនបានមានគោលការណ៍ជំទាស់នឹងការប្រើប្រាស់ឯកសាររបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏ក្ដីបារម្ភដ៏ចម្បងរបស់ពួកគេ គឺពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ក្នុងការទទួលយកភស្តុតាង ហើយថ្វីបើសហព្រះរាជអាជ្ញាមានការធ្វេសប្រហែសក្នុងការអនុលោមតាមវិធានផ្ទៃក្នុង ៨៧.៤ នេះ។ ដោយបានលើកឡើងពីបញ្ហាវិសមភាពរវាងភាគី មេធាវីការពារក្ដី **វើកគែន** (Vercken) បានអះអាងថា អង្គជំនុំជម្រះមិនគួរបង្ហាញនូវភាពបត់បែន ដែលលម្អៀងទៅកាន់ភាគីសហព្រះរាជអាជ្ញា នៅពេលដែលឯកសារអាចស្វែងរកបានរយៈពេលជាយូរយារណាស់មកហើយនោះ ហើយនៅពេលដែលមានក្ដីបារម្ភចំពោះសាក្សីដ៏សំខាន់រូបនេះផងដែរ។ លើសពីនេះទៅទៀត មេធាវី **វើកគែន** បានបន្ថែមទៀតថា អង្គជំនុំជម្រះជានិច្ចជាកាលតម្រូវឱ្យមេធាវីការពារក្ដី ដាក់សំណើបែបនេះជាលាយលក្ខណ៍អក្សរ។ មេធាវី **កូប៉េ** បានរម្លឹកឡើងជាថ្មីម្ដងទៀតថា គាត់រំពឹងទុកថា អង្គជំនុំជម្រះនឹងបង្ហាញពីភាពបត់បែនកម្រិតដូចគ្នានេះ ចំពោះក្រុមការពារក្ដី នៅគ្រប់កាលៈទេសៈដូចគ្នាផងដែរ។

ទីបំផុត អង្គជំនុំជម្រះបានទទួលយកនូវរូបថតពីរសន្លឹកនោះ ដោយបានបន្ថែមថា បញ្ជីឈ្មោះនៅមន្ទីរស-២១ បានដាក់បញ្ចូលទៅក្នុងភស្តុតាងរួចទៅហើយ។[40] ទោះបីជាយ៉ាងនេះក្ដី ក្នុងស្ថានភាពដែលធ្វើឲ្យមានការខកចិត្តនោះ សហព្រះរាជអាជ្ញា គឺមិនអាចប្រើរូបថតទាំងនោះ សម្រាប់គោលដៅកំណត់អត្តសញ្ញាណ ក្នុងអំឡុងពេលនៃការសួរដេញដោលបានឡើយ ដោយសារតែឈ្មោះរបស់បុគ្គលនោះ ត្រូវបានសរសេរនៅលើរូបថតនោះរួចទៅហើយ ដែលជាហេតុធ្វើឲ្យដំណើរការនៃការកំណត់អត្តសញ្ញាណប្រែទៅជាគ្មានន័យទៅវិញ។[41]

## ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

នាសប្ដាហ៍នេះ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មរបស់សាក្សីបួនរូបប្រកបដោយជោគជ័យ។ អង្គជំនុំជម្រះ បានប្រឹងប្រែងក្នុងការគ្រប់គ្រងលើវិសាលភាពនៃការតាំងសំណួរដេញដោលរបស់ភាគី ពេញមួយសប្ដាហ៍នេះ។ មានបញ្ហានៃការបកប្រែភាសា និងបញ្ហាឥរិយាបថក្នុងសវនាការមួយចំនួន បានកើតមានឡើងនៅសប្ដាហ៍នេះ ក៏ប៉ុន្តែ ជាទូទៅ អង្គជំនុំជម្រះបានគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៃសប្ដាហ៍នេះ ប្រកបដោយប្រសិទ្ធភាព។

### ក. វត្តមាន

ជនជាប់ចោទ **នួន ជា** បានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយ ពីបន្ទប់ឃុំឃាំងរបស់គាត់នៅក្រោមសាលសវនាការ ដោយសារតែបញ្ហាសុខភាព។ ជនជាប់ចោទ **ខៀវ សំផន** បានមានវត្តមាននៅក្នុងបន្ទប់សវនាការ ពេញមួយសប្តាហ៍។

**វត្តមានរបស់ចៅក្រម៖**

ចៅក្រម **យ៉ា សុខន** បានអវត្តមានពេញមួយសប្តាហ៍ ហើយត្រូវបានជំនួសដោយចៅក្រមបម្រុង **ធូ មុនី**។ មិនមានការប្រកាសទាក់ទងនឹងពេលវេលាដែលចៅក្រម **យ៉ា សុខន** អវត្តមាននោះទេ។

**វត្តមានដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **ពេជ្រ អង្គ** បានអវត្តមានពីថ្ងៃចន្ទ រហូតដល់ថ្ងៃពុធ ដោយសារតែហេតុផលផ្ទាល់ខ្លួន។ អ្នកឃ្លាំមើលសវនាការបានសង្កេតឃើញថា ជារៀងរាល់ថ្ងៃដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០នាក់ បានមានវត្តមាននៅក្នុងបន្ទប់សវនាការ និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនទៀត បានតាមដានកិច្ចដំណើរការនីតិវិធីពីសាលសាធារណជន។

**វត្តមានរបស់ភាគី៖**

ភាគីទាំងអស់ បានតំណាងឲ្យកូនក្តីរបស់ខ្លួន នៅក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍។

**វត្តមានរបស់សាធារណជន៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ<br>០១/០៧/១៣ | • សិស្សានុសិស្សចំនួន១៥០នាក់ មកពីខេត្តកំពង់ធំ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ | • សិស្សានុសិស្សចំនួន១៥០នាក់ មកពីខេត្តកំពង់ធំ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ១នាក់ |
| ថ្ងៃអង្គារ<br>០២/០៧/១៣ | • អ្នកភូមិចំនួន១៤០នាក់ មកពីខេត្តតាកែវ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៧នាក់ | • អ្នកភូមិចំនួន១៣០នាក់ មកពីខេត្តតាកែវ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៧នាក់ |
| ថ្ងៃពុធ<br>០៣/០៧/១៣ | • អ្នកភូមិចំនួន២០០នាក់ មកពីខេត្តតាកែវ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៦នាក់ | • សិស្សានុសិស្សចំនួន២០០នាក់ មកពីខេត្តតាកែវ<br>• ព្រះសង្ឃចំនួន ៧អង្គ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ |
| ថ្ងៃព្រហស្បតិ៍<br>០៤/០៧/១៣ | • អ្នកភូមិចំនួន១៥០នាក់ មកពីខេត្តកណ្តាល<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ | • សិស្សានុសិស្សចំនួន ៥០នាក់ មកពីខេត្តកំពង់ស្ពឺ និង ៥០នាក់ មកពីភ្នំពេញ<br>• ព្រះសង្ឃចំនួន ៤អង្គ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៦នាក់ |

### ខ. ការគ្រប់គ្រងពេលវេលា

នាសប្ដាហ៍នេះ អង្គជំនុំជម្រះ បានបន្តកិច្ចដំណើរការនីតិវិធីពីថ្ងៃចន្ទដល់ថ្ងៃព្រហស្បតិ៍ និងបានបញ្ចប់ការផ្ដល់សក្ខីកម្មរបស់សាក្សីចំនួនបួនរូប បានយ៉ាងជោគជ័យ។ ពេញមួយសប្ដាហ៍នេះ អង្គជំនុំជម្រះបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងតឹងរ៉ឹង ក្នុងការកំណត់ពេលវេលា ហើយបានកាត់សំណួរណាដែលមិនមានភាពទាក់ទងគ្នា ឬជាសំណួរច្រំដែល ឬក៏ជាសំណួរដែលមិនបានផ្ដោតលើប្រធានបទជាក់លាក់ណាមួយ ដែលទាក់ទងនឹងគោលបំណងក្នុងការកោះហៅសាក្សី។ អង្គជំនុំជម្រះ ក៏បានបដិសេធចំពោះការបន្ថែមពេលវេលាសម្រាប់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដីឲ្យជនជាប់ចោទ **ខៀវ សំផន** ផងដែរ។ អង្គជំនុំជម្រះ ក៏បានបង្ហាញពីចេតនា ក្នុងការកាត់បន្ថយពេលវេលាដែលនៅសេសសល់ នៅពេលដែលសាក្សី **ឯក ហេន** បានបញ្ចប់ការផ្ដល់សក្ខីកម្មរបស់គាត់នៅរសៀលថ្ងៃពុធនេះ សាក្សីបម្រុង **ស៊ុម អាឡាត់** ត្រូវបានកោះហៅឲ្យមកចូលខ្លួនដើម្បីធ្វើការសាកសួរដេញដោល ក្នុងរយៈពេល ៣០នាទី ចុងក្រោយនៃសវនាការថ្ងៃនោះ។

### គ. ឥរិយាបថក្នុងបន្ទប់សវនាការ

កាលពីថ្ងៃព្រហស្បតិ៍ ក្នុងអំឡុងពេលនៃការសាកសួរដេញដោលសាក្សី **ស៊ុម អាឡាត់** លោកប្រធានអង្គជំនុំជម្រះបានកាត់ផ្ដាច់ឧគ្ឃោសនសព្ទ (មីក្រូ) របស់មេធាវីការពារក្ដី **វែកគែន** ដោយបានអះអាងថាពេលវេលាបន្ថែមជូន ២០នាទីរបស់គាត់ត្រូវបានអស់ហើយ។ នៅពេលដែលមេធាវី **វែកគែន** បានព្យាយាមពន្យល់ថា គាត់កំពុងតែបញ្ចប់សំណួរចុងក្រោយរបស់គាត់ ឧគ្ឃោសនសព្ទរបស់គាត់ត្រូវបានកាត់ផ្ដាច់ជាថ្មីម្ដងទៀត ហើយលោកប្រធានអង្គជំនុំជម្រះបានរំសាយសាក្សី និងប្រកាសផ្អាកសវនាការ។

### ឃ. ការបកប្រែភាសា និងបញ្ហាបច្ចេកទេស

បញ្ហានៃការបកប្រែជាភាសាបារាំងមួយចំនួន ត្រូវបានគេកត់សម្គាល់ឃើញ ពេញមួយសប្ដាហ៍នេះ ជាពិសេស នៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍។

## ង.	តារាងពេលវេលា

| កាលបរិច្ឆេទ | សវនាការ ពេលព្រឹកវគ្គ១ | សវនាការ ពេលព្រឹកវគ្គ២ | សវនាការ ពេលរសៀលវគ្គ១ | សវនាការ ពេលរសៀលវគ្គ២ | ចំនួនម៉ោង សរុប |
|---|---|---|---|---|---|
| ថ្ងៃចន្ទ ០១/០៧/១៣ | ៩:០១-១០:៣០ | ១០:៥២-១២:១១ | ១៣:៣២-១៤:៤១ | ១៥:០២-១៥:៤១ | ៤ ម៉ោង ៣៦ នាទី |
| ថ្ងៃអង្គារ ០២/០៧/១៣ | ៩:០១-១០:៣១ | ១០:៥៣-១១:៤៩ | ១៣:៣៣-១៤:៤១ | ១៥:០០-១៦:០១ | ៤ ម៉ោង ៣៥ នាទី |
| ថ្ងៃពុធ ០៣/០៧/១៣ | ៩:០៤-១០:៤៤ | ១១:០១-១២:២០ | ១៣:៣៣-១៤:៤៤ | ១៥:០២-១៦:០២ | ៥ ម៉ោង ១០ នាទី |
| ថ្ងៃព្រហស្បតិ៍ ០៤/០៧/១៣ | ៩:០២-១០:៣០ | ១០:៥២-១១:៥៩ | ១៣:៣២-១៤:៣៨ | ១៥:០១-១៦:២៨ | ៥ ម៉ោង ០៨ នាទី |
| ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយថ្ងៃ៖ | | | ៤ម៉ោង និង៥២នាទី | | |
| ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ៖ | | | ១៩ម៉ោង និង២៩នាទី | | |
| ចំនួនសរុបនៃម៉ោងថ្ងៃនិងសប្តាហ៍៖ | | | ៨៨៣ម៉ោង និង១២នាទី | | |
| **សវនាការរយៈពេល១៩៩ថ្ងៃ ក្នុងអំឡុងពេល៦២សប្តាហ៍** | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

---

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Stephanie Fung, Andrew Grant, Melanie Hyde, Anne Lang, Jessica Mawrence, Aviva Nababan, Kimsan Soy, and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Proceedings (4 July 2013). E1/218.1 [hereinafter, 4 JULY TRANSCRIPT]. Lines 11-15. 22.

[2] Pech Chim was examined in the following order: President Nil Nonn; International Prosecutor Keith Raynor; Civil Party Lawyer Hong Kim; International Co-Lawyer for Nuon Chea Victor Koppe; National Co-Lawyer for Khieu Samphan Kong Sam Onn.

[3] 1 JULY TRANSCRIPT. Line 22. 35.

[4] 1 JULY TRANSCRIPT. Lines 13-14. 55.

[5] 1 JULY TRANSCRIPT. Lines 14-15. 57.

[6] The Witness named a military official named Som from Krang Ta Chan.

[7] 1 JULY TRANSCRIPT. Lines 7-15. 64.

[8] 1 JULY TRANSCRIPT. Lines 1-4. 9.

[9] The whole trip to Borei Keila lasted for one month but the study session only for about three weeks (20 days).

[10] Lev Lam was examined in the following order: President Nil Nonn; International Prosecutor Dale Lysak; National Prosecutor Seng Bungkheang; International Civil Party Lawyer Beini Ye; National Co-Lawyer for Nuon Chea Son Arun; International Co-Lawyer for Nuon Chea Victor Koppe; International Co-Lawyer for Khieu Samphan Arthur Vercken.

[11] Trial Chamber. Transcript of Trial Proceedings (2 July 2013). E1/216.1 [hereinafter, 2 JULY TRANSCRIPT]. Lines 2-6. 21.

[12] 2 JULY TRANSCRIPT. Lines 12-16. 21.

[13] Ek Hen was examined in the following order: President Nil Nonn; National Prosecutor Song Chorvoin; International Prosecutor Keith Raynor; National Civil Party Lawyer Sin Soworn; International Civil Party Lawyer Christine Martinneau; International Co-Lawyer for Nuon Chea Victor Koppe; International Co-Lawyer for Khieu Samphan Arthur Vercken.

[14] Trial Chamber. Transcript of Trial Proceedings (3July 2013). E1/217.1 [hereinafter, 3 JULY TRANSCRIPT]. Lines 23-24. 53.

[15] 3 JULY TRANSCRIP Trefers to Sao Phem as So Phim.

[16] 3 JULY TRANSCRIPT. Lines 1-4. 51.

[17] In her OCIJ statement, Ek Hen testified that she was made aware of the arrest of Pang in late 1976 when it was revealed Pang was consorting with the Vietnamese (referred to as Yuon). During her testimony in front of the court, however, Ek Hen insisted that she heard the term traitor for the first time during the second study session, which she had told the court was not until1978.

[18] 3 JULY TRANSCRIPT. Lines 9-11. 79.

[19] Sum Alatt was examined in the following order: President Nil Nonn; Deputy International Co Prosecutor William Smith; National Civil Party Lawyer Chet Vanly; ILCPL Simonneau Fort; National Co- Lawyer for Nuon Chea Son Arun; International Co-Lawyer for Nuon Chea Victor Koppe; International Co-Lawyer for Khieu Samphan Arthur Vercken.

[20] 4 JULY TRANSCRIPT. Lines 13-15. 7.

[21] 4 JULY TRANSCRIPT. Lines 24-25. 6.

[22] During his testimony, the Witness told counsel Vercken that he floated his uniform down the Pursat river. However, this was inconsistent with his OCIJ interview, where he stated that he was forced to turn it into KR soldiers in exchange for civilian clothes.

[23] See CASE 002 KRT TRIAL MONITOR, Issue 58, Hearing on Evidence Week 53 (29 April-3 March 2013).

[24] 4 JULY TRANSCRIPT. Lines 19-20. 80.

[25] 4 JULY TRANSCRIPT. Lines 14-15. 22.

[26] This was contrary to the account provided by Witness Ung Chhat.

[27] Witness So Socheat's testimony two weeks ago also raised the issue of the role of duty counsel, as her Duty Counsel had similarly attempted to defend her when she presented an unorthodox concluding statement. See CASE 002 KRT TRIAL MONITOR, Issue 63, Hearing on Evidence Week 58 (10- 14 June 2013).

[28] See Internal Rules of the Extraordinary Chambers InThe Courts of Cambodia, Revision 8, as revised on 3 August 2011.

[29] Lev Lam had stated in his OCIJ statement that thepeople he escorted to meet the District soldiers had been bludgeoned to death. See 2 JULY TRANSCRIPT. Lines 14-15. 30.

[30] 2 JULY TRANSCRIPT. Lines 15-18. 62.

[31] The President added that the topic of discussion wasthe killing of 17 April people who were former Lon Nol's military personnel or public servants at the Chrok Sangkay village execution site. Son Arun abruptly stated that he did not understand the President's explanation and promptly handed over the floor to his international counterpart.

[32] The ruling was preceded by objection from Khieu Samphan's National Counsel Kong Sam Onn. 3 JULY TRANSCRIPT. Lines 12-15. 56.

[33] 2 JULY TRANSCRIPT. Lines 2-4. 31.

[34] 3 JULY TRANSCRIPT. Lines 4-6. 95.

[35] 2 JULY TRANSCRIPT. Lines 7-9. 49.

[36] The rule governs the admittance of evidence at trial stage, which is subject to the Chamber's decisionand may be rejected if the proposed evidence is: a) irrelevant or repetitious, b) impossible to obtain within a reasonabletime, c) unsuitable to prove the facts it purports to prove, or d) is intended to prolong the proceedings or is otherwise frivolous.

[37] Nuon Chea's counsel pointed out that the Defense had already been flexible to accept the Prosecution's use of the documents despite their failure to include themin the interface by the 12.00 pm deadline on Tuesday.

[38] Prosecutor Song Chorvoin responded that the OCP had only received the photos from DC-CAM at 17.30 on the previous day. Song Chorvoin also reminded the Chamber that Ek Hen was originally scheduled to testify on July 25, and because his testimony was earlier than scheduled, the OCP could complete the application before the day of the testimony.

[39] Judge Cartwright confirmed with both Koppe and Verkcen that they had no principled objections to the Prosecution's use of the photographs and the S-21 prisoner list in their examination. See 3 JULY TRANSCRIPT. Lines 17-19. 11.

[40] President Nil Nonn ruled that as the list of S-21 prisoners was already used at prior stages of the trial, its use was again allowed during Witness examination. The President also explained that although the Rule 87.4criteria for new evidence was not satisfied with regards to the two photos, in the spirit of flexibility, the Chamber allowed them to be used as the Witness was ready to testify.

[41] As the Prosecution sought to confirm with Ek Hen thatone of the names present was that of her brother, who perished at S-21, Koppe pointed out that the name ofthe person was actually written on the photograph. Judge Cartwright on behalf of the Chamber sustained the Koppe's objection, stating that the evidence then had little value and the Prosecution could not rely on it for identification purposes.